# មជ្ឈមណ្ឌលឯកសារកម្ពុជា

# គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

# (១៩៧៥–១៩៧៩)

## ការចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

## វេទិកាសាធារណៈស្តីពីការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

## រវាងគ្រូ សិស្ស និងឪពុកម្តាយ

**ភូមិពង្រ ២ ឃុំពង្រ ស្រុកឆ្លូង ខេត្តក្រចេះ**

**ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១០**



*យុវជនចាមនៅក្នុងស្រុកឆ្លូង ខេត្តក្រចេះ*

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១០ គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រារព្ធធ្វើវេទិកាសាធារណៈស្តីពីការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យមួយនៅក្នុងភូមិពង្រ២ ឃុំពង្រ ស្រុកឆ្លូង ខេត្តក្រចេះ។ វេទិកានេះ បានប្រារព្ធធ្វើឡើងនៅក្នុងបរិវេណវិហារឥស្លាមមួយឈ្មោះ «អាល្លជីមាក់» ឬ «វិហារពង្រ» ដែលជាវិហារធំជាងគេនៅក្នុងខេត្តក្រចេះ។ អ្នកចូលរួមភាគច្រើនជាជនជាតិចាម ដែលរួមមានប្រជាជន ហាគីម(អ្នកដឹកនាំសហគមន៍ចាម) ទួន(អ្នកដឹកនាំសាសនា

ឥស្លាម) គ្រូបង្រៀន និងអាជ្ញាធរមូលដ្ឋាន ។ វេទិកានេះ បានចាប់ផ្តើមនៅវេលាម៉ោង៨ព្រឹក ហើយបញ្ចប់ទៅវិញនៅម៉ោង១១ព្រឹក ។ ក្នុងពេលបើកកម្មវិធី លោក ផេង ពង្សរ៉ាស៊ី បានប្រាប់ពីការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងគោលបំណងនៃការធ្វើវេទិកាសាធារណៈ ។ កម្មវិធីបន្ទាប់មកទៀត លោកជំទប់ទី១ឃុំពង្របានផ្តល់កិច្ចស្វាគមន៍ ដោយបានចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ក្នុងរបបខ្មែរក្រហមដល់អ្នកចូលរួម និងបានលើកទឹកចិត្តយុវជនចាមទាំងអស់ឲ្យខិតខំប្រឹងប្រែងសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ឲ្យក្លាយទៅជាផ្នែកមួយនៃវិជ្ជាជីវៈពិតប្រាកដទៅថ្ងៃអនាគតរបស់ខ្លួន ។ បន្ទាប់មកទៀត លោកឌី ខាំបូលី អ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បានធ្វើបទបង្ហាញរួម ទៅលើមាតិកាសៀវភៅប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍សំខាន់ៗដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។ ការធ្វើបទបង្ហាញនេះ ត្រូវបានធ្វើឡើង ដោយមានការចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងតារាងស្ទង់មតិមុនពេលធ្វើវេទិកា ដល់អ្នកចូលរួមទាំងអស់ឲ្យបំពេញ ដើម្បីចង់ដឹងពីការយល់ដឹង និងការចាប់អារម្មណ៍របស់អ្នកចូលរួមអំពីការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ។ បន្ទាប់មកទៀត រ៉ាស៊ី បានបង្រៀនជំពូក៤នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា "ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ" ដោយមានអមទៅដោយសំណួរ និងចម្លើយផង ។ នៅរសៀលថ្ងៃដដែល ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការសម្ភាសន៍អ្នកភូមិ គ្រូបង្រៀន និងយុវជនចាម ។

ទោះបីជាការរៀបចំធ្វើវេទិកាសាធារណៈស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យលើកទីប្រាំហើយក៏ដោយ តែនេះជាលើកទីមួយហើយដែលក្រុមការងារបានប្រារព្ធធ្វើវេទិកានេះនៅក្នុងសហគមន៍ចាម ។ វេទិកានេះបានប្រព្រឹត្តិទៅយ៉ាងល្អប្រសើរនៅក្នុងសហគមន៍ចាមនៅក្នុងស្រុកឆ្លូង ។ មេដឹកនាំសហគមន៍ បានសំដែងនូវទឹកចិត្តរីករាយថា យុវជនចាមមានឱកាសបានចូលរួមនៅក្នុងវេទិកាសាធារណៈនេះ ដែលផ្តល់ឲ្យខ្លួននូវចំណេះដឹងអំពីការសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម ក៏ដូចជាមានឱកាសបង្ហាញពីសមត្ថភាពខ្លួនឯងនៅក្នុងព្រឹត្តិការណ៍ដ៏មានសារសំខាន់ក្រោមការរៀបចំជាសាធារណៈមួយ ។ ការធ្វើវេទិកាសាធារណៈនេះបានជម្រុញនិងពង្រឹងការចូលរួមយ៉ាងសកម្មរបស់យុវជនឥស្លាម ព្រមទាំងជាការត្រួសត្រាយផ្លូវមួយសម្រាប់ការជ្រើសរើសការងារទៅថ្ងៃអនាគតរបស់ខ្លួននៅក្នុងកិច្ចការសង្គមទាំងមូល ។

## លក្ខណៈភូមិសាស្ត្រ

ឃុំពង្រ មានទីតាំងស្ថិតនៅចម្ងាយប្រហែល៣៥គីឡូម៉ែត្រពីទីរួមខេត្តក្រចេះ ។ ក្នុងចំណោមភូមិដែលមានប្រជាជនចាមរស់នៅចំនួន១៥ នៅក្នុងស្រុកឆ្លូង មានភូមិចំនួន៧ ជាភូមិចាស់ដែលមានតាំងពីមុនរបបខ្មែរក្រហមមកម្ល៉េះ ហើយភូមិចំនួន៨ផ្សេងទៀត គឺជាភូមិដែលទើបតែបង្កើតនៅក្រោយឆ្នាំ១៩៧៩ ។ ទោះជា

យ៉ាងនេះក្តី ក៏ភូមិដែលទើបបង្កើតថ្មីនេះ នៅតែមិនទាន់ទទួលបានការយល់ព្រមពីរដ្ឋាភិបាលជាផ្លូវការនៅឡើយទេ ។ ចំនួនប្រជាជនចាមដែលរស់នៅក្នុងស្រុកឆ្លូង គឺមានចំនួន៣.០០០គ្រួសារ ស្មើនឹងចំនួនជាង១៥០.០០០នាក់ ។ ដោយឡែក នៅក្នុងឃុំពង្រមានប្រជាជនចាមចំនួនប្រហែល៥.០០០នាក់ ។ ប្រជាជនទាំងនោះចូលចិត្តខ្លួនឯងថា "ចាម" ជាជាងហៅថា "ខ្មែរឥស្លាម" ពីព្រោះចាស់ទុំរបស់ខ្លួនគឺជាអ្នកដែលមានដើមកំណើតមកពីចំប៉ា ។

## ការព្រួយបារម្ភនៅមូលដ្ឋាន

លោក សា សូពៀត គឺជាប្រធានគណៈកម្មការយុវជនចាមនៅក្នុងស្រុកឆ្លូង ។ គណៈកម្មការនេះ ទើបតែបង្កើតថ្មីក្នុងគោលបំណងបង្រៀនយុវជនចាម និងលើកទឹកចិត្តអ្នកទាំងនោះឲ្យរៀនសូត្រ និងមិនគេចវេះសាលារៀន ។ តាមសម្តីរបស់លោក សា សូពៀត បានឲ្យដឹងថា អត្រាសិស្សដែលឈប់រៀន គឺមានភាគច្រើនជាសិស្សជនជាតិចាម ។ សិស្សជាជនជាតិចាមខ្លះ បានឈប់រៀនតាំងពីថ្នាក់ទី៦ ឬទី៧ម្ល៉េះ ។ អ្នកទាំងនោះមិនបានស្វែងយល់ឲ្យកាន់តែច្បាស់ពីតម្លៃនៃចំណេះដឹង និងការសិក្សាឡើយ ។ គណៈកម្មការនេះ ជួនកាលបានប្រារព្ធធ្វើវេទិកា និងវគ្គបណ្តុះបណ្តាលខ្លះៗ ដើម្បីលើកទឹកចិត្តយុវជនចាមឲ្យធ្វើការនៅក្នុងសាលារៀន ។ សមាជិកគណៈកម្មការតែងតែប្រាប់ទៅកាន់សិស្សឥស្លាមទាំងនោះឲ្យយកជាគំរូ ពីមេដឹកនាំឥស្លាមសំខាន់ៗមួយចំនួនដែលមានជោគជ័យក្នុងការសិក្សា ។ គណៈកម្មការនេះ ក៏ចង់បញ្ចូលប្រធានបទដែលទាក់ទងនឹងយេនឌ័រនៅក្នុងសហគមន៍ដែរ ។ លោក សូពៀត បានកត់សម្គាល់ថា ស្ត្រីចាមមិនមានចំណេះវិជ្ជាជ្រៅជ្រះប៉ុន្មានទេ ពីព្រោះអ្នកទាំងនោះមិនត្រូវបានលើកទឹកចិត្តឲ្យរៀនសូត្រ ។ សហគមន៍ទាំងមូលហាក់ដូចជាគិតគូរខ្លាំងតែទៅលើបុរសចាមទៅវិញ ។ ទោះជាយ៉ាងនេះក៏ដោយ ស្ត្រីចាមមួយចំនួនបានក្លាយទៅជាគ្រូបង្រៀននៅក្នុងអនុវិទ្យាល័យ និងវិទ្យាល័យផ្សេងៗគ្នានៅក្នុងស្រុក ។

ដោយសារតែក្មេងៗជនជាតិឥស្លាមភាគច្រើនបានឈប់រៀនបែបនេះ ទើបគណៈកម្មការយុវជនឥស្លាមបង្កើតសាលាសាសនាមួយនៅក្នុងបរិវេណវិហារពង្រ ដែលមាន៦ថ្នាក់ និងសិស្សចូលរៀនចំនួន៤០០នាក់ ។ គ្រូបង្រៀន (ទូន) ត្រូវបានជ្រើសរើសចេញពីប្រជាជនដែលមានចំណេះដឹងនៅក្នុងភូមិ ។ ចំណែកគ្រូបង្រៀនផ្សេងទៀត គឺមកពីប្រទេសអារ៉ាប់ ។ គ្រូបង្រៀនទាំងនោះ គឺចាប់ផ្តើមធ្វើការដំបូងតាមរយៈការស្ម័គ្រចិត្ត ។ បន្ទាប់មក ទើបគណៈកម្មការយុវជនឥស្លាមធ្វើការរៃអង្គាសថវិកាពីអ្នកភូមិមកជួយគ្រូបង្រៀនទាំងនោះ ដើម្បីចិញ្ចឹមជីវិត ។ សាលានេះ ផ្តោតសំខាន់ទៅលើការសិក្សាភាសាអារ៉ាប់និងម៉ាឡេស៊ី សាសនាអ៊ីស្លាម និងចំណេះដឹងពីសង្គម ។ បន្ថែមពីនេះទៀត គណៈកម្មការនេះមានគម្រោងបង្កើតដៃគូរមួយដែលមានទាំងរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីរៀបចំវេទិកាសាធារណៈ និងដំណើរទស្សនកិច្ចសម្រាប់យុវជនឥស្លាមទៅកាន់ទីតាំងប្រល័យពូជសាសន៍មួយចំនួនដូចជា សារមន្ទីរទួលស្លែង និងវាលពិឃាតបឹងជើងឯកជាដើម ។ គណៈកម្មការ

នេះចង់ឲ្យយុវជនចាមស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងផលប៉ះពាល់ពីរបបនេះទៅលើសហគមន៍ខ្លួន ។ ការធ្វើទស្សនកិច្ចទៅកាន់ទីតាំងប្រល័យពូជសាសន៍ទាំងនោះ មិនត្រឹមតែធ្វើឲ្យយុវជនចាមបង្កើនចំណេះដឹងពីសង្គមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតនូវទម្រង់មួយដែលយុវជនឥស្លាមអាចបង្កើតនូវទំនាក់ទំនងជាមិត្តភាព ដើម្បីពង្រឹងសហគមន៍របស់ខ្លួនទៀតផង ។

## ប្រវត្តិវិហារឥស្លាមនៅក្នុងឃុំពង្រ

ក្នុងរបបខ្មែរក្រហម ប្រជាជនឥស្លាមនៅក្នុងឃុំពង្រត្រូវបានជម្លៀសឲ្យទៅរស់នៅ និងធ្វើការនៅក្នុងស្រុកព្រៃកប្រសប់ ស្ថិតនៅត្រើយម្ខាងទន្លេមេគង្គ ។ តាមសម្តីរបស់ សូពៀត បានឲ្យដឹងថា ប្រជាជនចាមបានជួយគាំទ្រយ៉ាងពេញទំហឹងដល់ខ្មែរក្រហមនៅមុនថ្ងៃទទួលបានជ័យជំនះកាលពីឆ្នាំ១៩៧៥ ។ អ្នកទាំងនោះបានចូលរួមជាកម្លាំងជាមួយខ្មែរក្រហមក្នុងការវាយប្រហារកងកម្លាំងធីវគីនៅក្នុងអំឡុងឆ្នាំ១៩៧១ ។ ភូមិមួយរបស់ចាម ត្រូវបានដាក់ឈ្មោះថា "ភូមិតស៊ូ" ដោយខ្មែរក្រហម ពីព្រោះប្រជាជនដែលរស់នៅទីនោះមិនបានរត់គេចពីការវាយប្រហាររបស់កងកម្លាំងសាធារណៈរដ្ឋខ្មែរ និងការទម្លាក់គ្រាប់បែករបស់អាមេរិកឡើយ ។ អ្នកទាំងនោះបានរស់នៅក្នុងភូមិ និងបានវាយតបតនឹងសត្រូវវិញ ។ នៅពេលមួយនោះ កងកម្លាំងធីវគីបានចូលមកក្នុងភូមិ និងបានដុតផ្ទះសម្បែងប្រជាជន ។ លើសពីនេះទៀត មានចាមមួយចំនួនគឺស្ថិតនៅក្នុងជួរកម្មាភិបាលជាន់ខ្ពស់របស់ខ្មែរក្រហមដែរដូចជា ម៉ាត់ លី ជាដើម ។ សូពៀត បាននិយាយថា គាត់បានជួប ម៉ាត់ លី ពីរបីដងនៅក្រោយឆ្នាំ១៩៧៥ ។ ម៉ាត់ លី និងកម្មាភិបាលរបស់គាត់ បានមកកាន់ភូមិនេះ និងបានឃោសនាអ្នកភូមិឲ្យចូលបម្រើបដិវត្តន៍របស់ខ្មែរក្រហម ។ សូពៀត បាននិយាយថា ក្រុមរបស់ ម៉ាត់ លី បានប្រើប្រាស់សិល្បៈជាមធ្យោបាយឃោសនាបដិវត្តន៍របស់ខ្លួន ។ ពេលខ្លះ ម៉ាត់ លី បានស្នាក់នៅភូមិរបស់គាត់ (សូពៀត) ពីរបីខែ ។

ទោះជាប្រជាជនចាមបានផ្តល់ដល់ខ្មែរក្រហមនូវជំនួយការយ៉ាងច្រើននៅមុនឆ្នាំ១៩៧៥ក៏ដោយ ក៏អ្នកទាំងនោះត្រូវបានប្រព្រឹត្តិមកលើវិញយ៉ាងឃោរឃៅបំផុតនៅក្នុងចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩ ។ ប្រជាជនចាមទាំងនោះ ត្រូវបានបង្ខំឲ្យផ្លាស់ប្តូរផ្ទះសម្បែងជាមួយនឹងប្រជាជនខ្មែរ ឬបង្ខំឲ្យរស់នៅជាមួយគ្រួសារខ្មែរក្រោមដំបូលតែមួយ ។ វិហារដ៏ចំណាស់មួយ ត្រូវខ្មែរក្រហមយកធ្វើជាផ្ទះបាយ ។ ជនជាតិចាមទាំងនោះត្រូវបានបង្ខំឲ្យលុបបំបាត់សាសនា និងអត្តសញ្ញាណខ្លួនឯង ។ ជាញឹកញាប់ ប្រជាជនចាមត្រូវបានបង្ខំឲ្យហូបសាច់ជ្រូក ដែលបណ្តាលឲ្យក្អួត ។ ប្រជាជនចាមមួយចំនួនត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហម ។

នៅក្រោយឆ្នាំ១៩៧៩ ប្រជាជនចាម ក៏ដូចជាប្រជាជនខ្មែរទូទាំងប្រទេសដែរ បានវិលត្រឡប់មកកាន់ស្រុកកំណើតវិញ និងបានបន្តការប្រណិបត្តិសាសនាឥស្លាមវិញ ។ ដោយសារតែវិហារពីមុនមានអាយុចាស់ណាស់ទៅហើយ ប្រជាជនចាមនៅក្នុងភូមិបានសម្រេចចិត្តកសាងវិហារថ្មីទៀតនៅក្នុងឆ្នាំ១៩៨៥ ។ ការ

កសាងនេះ ទទួលបានការឧបត្ថម្ភពីប្រជាជនចាមនៅក្នុងឃុំពង្រទាំងមូល ។ យោងតាមសម្តីរបស់ សូពៀត ប្រជាជនចាមម្នាក់ៗ បានសន្សំអង្ករមួយក្តាប់ដែលយកចេញពីអង្ករដែលត្រូវដាំបាយហូបជារៀងរាល់ថ្ងៃ ទុកដើម្បីកសាងវិហារ ។ បន្ថែមពីនេះទៀត ប្រភពថវិកាផ្សេងទៀត គឺបានមកពីកម្លាំងពលកម្មរបស់អ្នកភូមិ ។ នៅក្នុងរដូវប្រាំង ទឹកទន្លេមេគង្គគឺមានសភាពរាក់ ។ កាណូតដែលធ្វើដំណើរមកពីភ្នំពេញឆ្លងកាត់ទៅកាន់ខេត្តក្រចេះ តែងតែជាប់គៀងនៅក្បែរភូមិចាម ។ ប្រជាជនចាមបានជួយរុញកាណូតដែលជាប់គៀងនេះ ។ ដើម្បីជាថ្នូរក្នុងការជួយនេះ ប្រជាជនចាមទាំងនោះបានទទួលនូវថវិកាខ្លះពីម្ចាស់ទូកកាណូត ។ ថវិកាទាំងនេះ ត្រូវបានសន្សំទុកដើម្បីកសាងវិហារដែរ ។ សកម្មភាពទាំងនេះ បានបង្ហាញពីទំនាក់ទំនងយ៉ាងរឹងមាំ និងជាសហគមន៍តឹងរ៉ឹងមួយ នៅក្នុងចំណោមជនជាតិចាមទាំងមូល ។ ក្នុងពេលបច្ចុប្បន្ននេះ សហគមន៍ចាមនៅក្នុងឃុំពង្រ បានទទួលជំនួយមកពីប្រជាជនចាមរស់នៅឯបរទេស និងអង្គការសាសនាមូស្លីមនៅប្រទេសអារ៉ាប់និងម៉ាឡេស៊ី ។

## សកម្មភាពក្នុងពេលធ្វើវេទិកា

### ១) ការបើកកម្មវិធីវេទិកា ដោយលោក ដេង ពង្សរ៉ាស៊ី

លោក ដេង ពង្សរ៉ាស៊ី បានបើកកម្មវិធីវេទិកាសាធារណៈដោយបានពន្យល់ពីកិច្ចការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងគោលបំណងនៃគម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ រ៉ាស៊ី បានចាប់ផ្តើមថា គម្រោងមានបំណងចង់នាំមកនូវការកសាងសន្តិភាព ការផ្សះផ្សាថ្នាក់ជាតិ និងការការពារអំពើប្រល័យពូជសាសន៍ សម្រាប់សង្គមជាតិទាំងមូល ។ រ៉ាស៊ី បានសួរទៅអ្នកចូលរួមឲ្យរកអត្ថន័យដែលទាក់ទងនឹងពាក្យ ប្រល័យពូជសាសន៍ ។ អ្នកចូលរួមបានផ្តល់ចម្លើយផ្សេងៗគ្នា ។ អ្នកចូលរួមម្នាក់បានឆ្លើយថា *"អំពើប្រល័យពូជសាសន៍ គឺជាសកម្មភាពនៃការសម្លាប់មនុស្ស"* ។ អ្នកចូលរួមជាជនជាតិចាមម្នាក់ទៀតបានឆ្លើយថា *"អំពើប្រល័យពូជសាសន៍មានន័យថា ខ្មែរក្រហមបានធ្វើទុក្ខបុកម្នេញលើប្រជាជន និងមិនអនុញ្ញាតិឲ្យប្រជាជនគោរពតាមប្រពៃណីសាសនារបស់ខ្លួន"* ។ រ៉ាស៊ី ក៏បានពន្យល់ថា "អំពើប្រល័យពូជសាសន៍ គឺជាចេតនាសម្លាប់ក្រុមណាមួយទាំងមូល ឬសមាជិកនៃក្រុមនោះ" ។

រ៉ាស៊ី បានពន្យល់បន្ថែមថា គោលបំណងសំខាន់នៃគម្រោងនេះ គឺដើម្បីការពារអំពើប្រល័យពូជសាសន៍មិនឲ្យកើតឡើងជាថ្មីម្តងទៀតទៅអនាគត ។ គាត់បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានចំណាយពេលវេលាបីឆ្នាំតាំងពីឆ្នាំ២០០៤រហូតដល់ឆ្នាំ២០០៧ ដើម្បីបោះពុម្ពសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។ សៀវភៅនេះ បានទទួលការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡាថាជាឯកសារយោងយ៉ាងសំខាន់មួយដើម្បីសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យនៅក្នុងប្រទេសកម្ពុជា ។ សៀវភៅប្រវត្តិសាស្ត្រនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់ក្រសួង ។ រ៉ាស៊ី ក៏បាននិយាយដែរអំពីវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ គ្រូឧទ្ទេសថ្នាក់ខេត្ត និងគ្រូមូលដ្ឋានបង្រៀន

មុខវិជ្ជាប្រវត្តិវិទ្យា ព្រមទាំងបានបញ្ជាក់ពីគម្រោងផែនការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនជាង៣០០០នាក់នៅក្នុងទូទាំងប្រទេសកម្ពុជា ។ គ្រូខុទ្ទេសថ្នាក់ខេត្តម្នាក់នៅខេត្តក្រចេះ ក៏បានចូលរួមនៅក្នុងវេទិកានេះដែរ ។

បន្ទាប់មក វ៉ាសុី បានបន្តការពន្យល់ពីគោលបំណងនៃការធ្វើវេទិកាសាធារណៈ ដែលរួមបញ្ចូលទាំងការចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់អ្នកចូលរួមទាំងអស់ និងការពិភាក្សាលើមាតិកាសៀវភៅប្រវត្តិសាស្ត្រផង ។ វ៉ាសុី បានបន្តថ្លែងថា វេទិកាសាធារណៈនេះគឺជាទម្រង់នៃការពិភាក្សាដ៏សំខាន់មួយរវាងក្មេងជំនាន់ក្រោយ និងអ្នកចាស់ទុំរបស់ខ្លួនអំពីរបបខ្មែរក្រហម ។ ប្រជាជនមានចំណេះដឹង និងបទពិសោធន៍អំពីប្រវត្តិសាស្ត្រខ្មែរក្រហមខុសៗគ្នា ។ កម្រិតនៃការយល់ដឹង ក៏ផ្សេងៗគ្នាដែរ ។ ម្យ៉ាងវិញទៀត ប្រជាជនភាគច្រើន ជាពិសេសសិស្សានុសិស្ស ដែលរស់នៅក្នុងទីជនបទឆ្ងាយៗនៃប្រទេសកម្ពុជា មិនទាន់ទទួលបានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅឡើយទេ ។ វេទិកាសាធារណៈនេះ ក៏មានបំណងក្នុងការនាំយកនូវការផ្សះផ្សាជាតិ ដោយធ្វើឲ្យជនរងគ្រោះ និងជនដៃដល់ស្វែងយល់ពីគ្នាទៅវិញទៅមកអំពីមូលហេតុដែលបានកើតឡើងនាពេលកន្លងមក ដើម្បីឲ្យអ្នកទាំងនោះអាចរស់នៅក្នុងភូមិតែមួយដូចគ្នាបាន ។

## ២) សន្ទរកថារបស់លោក គីរីណឹប ជាជំទប់ទី១ឃុំពង្រ

លោកជំទប់ទី១ឃុំពង្រ បានថ្លែងមតិស្វាគមន៍ចំពោះភ្ញៀវទាំងអស់ និងយុវជនឥស្លាមដែលចូលរួមនៅក្នុងវេទិកានេះ ។ គាត់បាននិយាយថា *«ថ្ងៃនេះ ឃុំពង្រមានកិត្តិយសជាខ្លាំងដោយបានមជ្ឈមណ្ឌលឯកសារកម្ពុជាជ្រើសរើសធ្វើវេទិកាសាធារណៈនៅទីនេះ»* គាត់បានបន្តថា របបខ្មែរក្រហមគឺពិតជារបបឃោរឃៅដែលបានបង្ខំឲ្យប្រជាជនទាំងក្មេងទាំងចាស់ធ្វើការងារហួសកម្លាំង ។ លោកជំទប់ទី១ឃុំ ក៏បានលើកទឹកចិត្តជាខ្លាំងចំពោះក្មេងៗជំនាន់ក្រោយឲ្យផ្តោតការយកចិត្តទុកដាក់ឲ្យមែនទែនចំពោះការធ្វើវេទិកានៅព្រឹកនេះ ដើម្បីបានស្វែងយល់ឲ្យកាន់តែច្រើនថែមទៀតអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។

## ៣) បទបង្ហាញអំពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយលោក ឌី ខាំបូលី

មុនពេលធ្វើបទបង្ហាញដោយសង្ខេបអំពីសៀវភៅប្រវត្តិសាស្ត្រ បូលី បានសួរទៅកាន់អ្នកចូលរួមទាំងអស់ថា តើមានបានឃើញសៀវភៅប្រវត្តិសាស្ត្រនេះពីមុនដែរឬទេ! ។ យុវជនមួយចំនួនបានលើកដៃ ពីព្រោះពួកគេធ្លាប់បានសិក្សានៅក្នុងថ្នាក់ និងបានឃើញនៅក្នុងបណ្ណាល័យ ។ បន្ទាប់មក បូលី សួរថា *«នៅពេលដែលខ្មែរក្រហមកាន់កាប់អំណាច តើខ្មែរក្រហមបានធ្វើអ្វីខ្លះ ?»* យុវជនម្នាក់បានឆ្លើយថា *«ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងបណ្តាទីប្រជុំជនផ្សេងទៀតទៅកាន់ទីជនបទ ។»* យុវនារីម្នាក់ទៀតបានឆ្លើយថា *«នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ពួកគេបានបង្ខំប្រជាជនឲ្យធ្វើការ ទោះបីជាប្រជាជនទាំងនោះជាអ្នកមាន ឬអ្នកក្រក៏ដោយ» ។ ខ្មែរក្រហមបានធ្វើទារុណកម្មមកលើប្រជាជន» ។*

បន្ទាប់មក បូលី បានធ្វើបទបង្ហាញអំពីសៀវភៅប្រវត្តិសាស្ត្រដែលបានបោះពុម្ពដំបូងនៅឆ្នាំ២០០៧

ដែលមាន១១ជំពូក ។ សៀវភៅនេះ បានរៀបរាប់អំពីការកកើត ការកាប់កាប់អំណាច និងការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សៀវភៅនេះ ក៏បានឆ្លើយទៅនឹងសំណួរដែលបានសួរទាក់ទងទៅនឹងការកកើតរបបកម្ពុជាប្រជាធិបតេយ្យដំបូងដែរ ។ តើនរណាជាអ្នកដឹកនាំរបបខ្មែរក្រហម? តើពាក្យថា "ខ្មែរក្រហម" កើតចេញមកពីណា? តើខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនកម្ពុជាអ្វីខ្លះ ក្នុងពេលដែលខ្លួនកាន់កាប់អំណាច? តើហេតុផលអ្វីដែលបណ្តាលឲ្យរបបខ្មែរក្រហមត្រូវបានដួលរលំ?

បន្ទាប់មកទៀត បូលី បានលើកឡើងអំពីការធ្វើបាបរបស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជា ក៏ដូចជាប្រជាជនឥស្លាម ។ បូលី បានលើកទឹកចិត្តយុវជនចាមឲ្យស្វែងរកចម្លើយតាមរយៈការសួរនាំទៅកាន់ឪពុកម្តាយ និងចាស់ទុំរបស់ខ្លួន ។ បូលី ក៏បានលើកឧទាហរណ៍ពីលោក សូពៀត ដែលជាប្រធានគណៈកម្មការយុវជនឥស្លាមនៅក្នុងស្រុកឆ្លូង ថាជាយុវជននៅក្នុងរបបខ្មែរក្រហម ។ ប្រជាជនឥស្លាម គឺមិនត្រូវឲ្យរស់នៅក្នុងសហគមន៍របស់ខ្លួនឡើយ ។ អ្នកទាំងនោះ ត្រូវបានបង្ខំឲ្យរស់នៅលាយឡំជាមួយនឹងប្រជាជនខ្មែរ និងមិនត្រូវបានអនុញ្ញាតិឲ្យប្រកាន់ខ្ជាប់នូវអត្តសញ្ញាណរបស់ខ្លួនឡើយ ។ លើសពីនេះទៀត សិទ្ធិទាំងអស់ ត្រូវបានហាមឃាត់ ។ ជនជាតិចាមត្រូវបានបង្ខំឲ្យហូបសាច់ជ្រូក ដែលជាការប្រឆាំងទៅនឹងសាសនាឥស្លាម ។ បន្ទាប់មក បូលី បានពន្យល់ថា ការសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាការទប់ស្កាត់ និងការបង្ការកុំឲ្យរបបនេះកើតមានម្តងទៀតនៅកម្ពុជា ។ ការសិក្សានេះ ក៏ជាការផ្តល់នូវការផ្សះផ្សាជាតិ និងព្យាបាលរបួសផ្លូវចិត្តដែរ ។ បូលី បានលើកទឹកចិត្តអ្នកចូលរួមទាំងអស់ឲ្យយកចិត្តទុកដាក់ទៅលើការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ បូលី បានលើកយកបទពិសោធន៍ពីជីវិតរបស់កញ្ញា ហ្វារីណា ដែលបច្ចុប្បន្នជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា យ៉ាងសង្ខេបមកប្រាប់ដល់អ្នកចូលរួមទាំងអស់ស្តាប់ ដើម្បីជាឧទាហរណ៍ ។ បូលី បានប្រាប់យុវជនចាមទាំងអស់ថា ហ្វារីណា គឺជាក្មេងស្រីម្នាក់ដែលកើតនៅក្នុងស្រុកទាបក្នុងគ្រួសារក្រីក្រមួយដូចអ្នកឯទៀតដែលបានចូលរួមនៅក្នុងការធ្វើវេទិកានៅថ្ងៃនេះអញ្ចឹងដែរ ។ នាងបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតរបស់ខ្លួននៅសហរដ្ឋអាមេរិក រួចបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ និងបានដឹកនាំគម្រោងមួយដែលធ្វើការជាមួយនឹងវិហារឥស្លាមទាំងអស់នៅក្នុងទូទាំងប្រទេសកម្ពុជា ។ បូលី បានជម្រុញឲ្យយុវជនចាមទាំងអស់យកគំរូតាមហ្វារីណា និងទុកនៅក្នុងចិត្តសម្រាប់ជាការលូតលាស់ផ្ទាល់ខ្លួន ។

បន្ទាប់ពីការថ្លែងដោយសង្ខេបរបស់ បូលី រួចមក សមាជិកក្រុមទាំងអស់បានចែកតារាងស្ទាបស្ទង់មតិមុនពេលធ្វើវេទិកា ដល់អ្នកចូលរួមទាំងអស់ឲ្យបំពេញ ដើម្បីចង់វាស់ស្ទង់ចំណេះដឹង ការចាប់អារម្មណ៍ និងអាកប្បកិរិយារបស់អ្នកទាំងនោះ ឆ្ពោះទៅរកការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ។

### ៤) បទបង្ហាញជំពូក៤ ដោយលោក ផេង ពង្សរ៉ាស៊ី

រ៉ាស៊ី បានបែងចែកអ្នកចូលរួមទៅជា៦ក្រុម ដើម្បីអាច៦ចំណុចផ្សេងគ្នានៅក្នុងជំពូក៤ ។ ក្រុមនីមួយៗត្រូវតែជ្រើសរើសអ្នកតំណាងម្នាក់ក្នុងការឡើងធ្វើសេចក្តីសង្ខេបទៅលើប្រធានបទរបស់ខ្លួន ។

- ក្រុមទី១ អានចំណុច "អង្គការ" និង "រចនាសម្ព័ន្ធដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ" ។
- ក្រុមទី២ អានចំណុច "ការយាងនិវត្តន៍មកដល់កម្ពុជារបស់សម្តេចព្រះ នរោត្តម សីហនុ" ។
- ក្រុមទី៣ អានចំណុច "សម្តេចព្រះនរោត្តម សីហនុ លាលែងពីតំណែងប្រមុខរដ្ឋ" ។
- ក្រុមទី៤ អានចំណុច "រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ" និង "ការផ្លាស់ប្តូរថ្ងៃកំណើតបក្ស ។
- ក្រុមទី៥ អានចំណុច "បទចំរៀងកម្ពុជាប្រជាធិបតេយ្យ", "ទង់ជាតិកម្ពុជាប្រជាធិបតេយ្យ", "សញ្ញាជាតិកម្ពុជាប្រជាធិបតេយ្យ" ។
- ក្រុមទី៦ អានចំណុច "ប្រវត្តិរូបសង្ខេបរបស់ ខៀវ សំផន ហៅ សមមិត្ត ហែម" ។

អ្នកចូលរួមទាំងអស់ត្រូវបានផ្តល់រយៈពេលចំនួន១៥នាទីក្នុងការអានចំណុចមួយៗរបស់ក្រុមខ្លួន រួមទាំងការកត់ត្រាព្រឹត្តិការណ៍សំខាន់ៗចេញពីការអាន ។ បន្ទាប់ពីការអាន ក្រុមនីមួយៗបានជ្រើសរើសតំណាងក្រុមរបស់ខ្លួនឲ្យឡើងសង្ខេបពីចំណុចដែលបានសង្ខេប ។

**ក្រុមទី១** ៖ *យុវនារីម្នាក់បានឡើងមកខាងមុខ និងធ្វើការសង្ខេបដូចតទោះ "ទោះបីជាខ្មែរក្រហមធ្វើចម្បាំងប្រឆាំងនឹងរបបសាធារណៈរដ្ឋខ្មែររបស់លោកសេនាប្រមុខ លន់ នល់ អស់រយៈពេលប្រាំឆ្នាំក៏ដោយ ក៏ចលនា និងមេដឹកនាំសំខាន់ៗរបស់ខ្មែរក្រហមមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈដែរ ។ សមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជាក្នុងឆ្នាំ១៩៧៥ រួមមានប៉ុល ពត, នួន ជា, សោភឹម, អៀង សារី, សុន សេន, តាម៉ុក, និងវ៉ន វ៉េត ។ នៅក្នុងឆ្នាំ១៩៧៧ សមាជិកបីរូបទៀតត្រូវបានបញ្ចូលទៅក្នុងគណៈកម្មាធិការនេះ ។ អ្នកទាំងបីគឺ ញឹម រស់, ខៀវ សំផន និងកែ ពក ។ សមាជិកនៅក្នុងក្រុមស្ត្រីម្នាក់ទៀតបានបន្ថែមថា សមាជិករបស់បក្សកុំម្មុយនីស្តកម្ពុជា ក៏មានតំណែងនៅក្នុងរដ្ឋាភិបាលដែរ ។ ឧទាហរណ៍ ក្រសួងការបរទេសដឹកនាំដោយ អៀង សារី ។ ក្រសួងការពារជាតិ ដឹកនាំដោយ សុន សេន ។ ក្រសួងឧស្សាហកម្ម ដឹកនាំដោយ ចេង អន និងក្រសួងសេដ្ឋកិច្ច ដឹកនាំដោយ វ៉ន វ៉េត ។*

**ក្រុមទី២** ៖ *ក្រុមនេះពិភាក្សាអំពីការយាងចូលមកកម្ពុជាវិញរបស់សម្តេចព្រះនរោត្តម សីហនុ ។ យុវនារីម្នាក់តំណាងឲ្យក្រុមរបស់ខ្លួនឡើងមកធ្វើការសង្ខេបថា រហូតមកដល់ឆ្នាំ១៩៧២ ខ្មែរក្រហមនៅតែហៅខ្លួនឯងថាជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ ដើម្បីចំណេញដល់ការគាំទ្រពីប្រជាជននិងសហគមន៍អន្តរជាតិ ខ្មែរក្រហមនៅតែធ្វើការក្រោមអធិបតីភាពរបស់សម្តេចព្រះនរោត្តម សីហនុ ដដែល ។ នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានយាងសម្តេចឲ្យមកកាន់ប្រទេសវិញ ។ សម្តេច គឺស្ថិតនៅក្នុងការនិរទេសខ្លួននៅក្នុងប្រទេសកូរ៉េខាងជើង និងប្រទេសចិន ។ ព្រះអង្គបានយាងនិវត្តន៍នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ជាមួយនឹងព្រះមហេសីព្រះអង្គដែលអមដំណើរដោយសម្តេច ប៉ែន នុត ជាអតីតនាយករដ្ឋមន្ត្រី ។*

**ក្រុមទី៣** ៖ ក្រុមនេះបានធ្វើការសន្និបថា សម្តេចព្រះ នរោត្តម សីហនុ បានលាលែងចេញពីតំណែងពីប្រមុខរដ្ឋនៅថ្ងៃទី១១ ខែមិនា ឆ្នាំ១៩៧៦ ។ គណៈកម្មាធិការមជ្ឈិមបក្ស បានប្រជុំដើម្បីពិភាក្សាពីការសុំលាលែងចេញពីតំណែងរបស់ព្រះអង្គ ។ សមាជិកគណៈកម្មាធិការបានសម្រេចយល់ព្រមតាមសំណើរនេះ ប៉ុន្តែព្រះអង្គមិនត្រូវបានអនុញ្ញាតិឲ្យចេញក្រៅប្រទេសឡើយ ។ របបរាជានិយមដែលបានកើតឡើងនៅកម្ពុជាអស់រយៈពេលជិត២០០ឆ្នាំមកហើយ គឺបានមកដល់ទីបញ្ចប់ហើយ ។ នៅខែមេសា ឆ្នាំ១៩៧៦



សភាតំណាងប្រជាជនរបស់ខ្មែរក្រហម បានបើកសម័យប្រជុំពេញអង្គតែម្តងគត់របស់ខ្លួន ។ បន្ទាប់ពីការលាឈប់របស់ព្រះអង្គ សម្តេចព្រះនរោត្តម សីហនុគឺត្រូវស្ថិតជាប់ឃុំនៅក្នុងព្រះបរមរាជវាំងរហូតដល់ខែមករា ឆ្នាំ១៩៧៩ ដែលជាថ្ងៃដួលរលំរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ យុវនារីនៅក្នុងក្រុមដដែលម្នាក់ទៀតបានធ្វើសេចក្តីសន្និបដូចតទៅ៖ *«សភាតំណាងប្រជាជន បានយល់ព្រមតាមសំណើររបស់ព្រះអង្គក្នុងការលាលែងតំណែង ។ សភាបានផ្តល់ប្រាក់សោធននិវត្តន៍ដល់ព្រះអង្គចំនួន៨០០០ដុល្លាសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ ប៉ុន្តែព្រះអង្គមិនដែលបានទទួលប្រាក់ទាំងនេះឡើយ ។ ព្រះអង្គ និងព្រះរាជវង្សានុវង្សត្រូវបានឃុំខ្លួននៅក្នុងព្រះបរមរាជវាំង»* ។

**ក្រុមទី៤** ៖ ក្រុមនេះពិភាក្សាអំពីរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានអនុម័តដោយសមាជិកចំនួន១០០០នាក់នៅក្នុងទីក្រុងភ្នំពេញ ។ រដ្ឋធម្មនុញ្ញនេះ គឺត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ។ បន្ទាប់មកទៀត ប្រទេសកម្ពុជាត្រូវបានផ្លាស់ប្តូរឈ្មោះជាផ្លូវការថា កម្ពុជាប្រជាធិបតេយ្យ ។ យុវជនម្នាក់ទៀត បានធ្វើការពិភាក្សាពីការផ្លាស់ប្តូរថ្ងៃកំណើតបក្សកុំម្មុយនីស្តកម្ពុជា ។ យុវជននោះបាននិយាយថា *«មេដឹកនាំខ្មែរក្រហមបានកំណត់យកឆ្នាំ១៩៦០ធ្វើជាថ្ងៃកំណើតបក្ស ។ នរណាដែលចូលបក្សមុនថ្ងៃនេះ គឺមិនត្រូវបានរាប់បញ្ចូលជាសមាជិកបក្សទៀតទេ ។ បក្សកុំម្មុយនីស្តកម្ពុជាត្រូវបានចាត់ទុកថាជាអង្គការ ។ នៅក្នុងឆ្នាំ១៩៧៧ បន្ទាប់ពីការវិលត្រឡប់ពីដំណើរទស្សនកិច្ចនៅបរទេសរួចមក ប៉ុល ពត បានថ្លែងពីស្ថេរភាពនៃបក្សកុំម្មុយនីស្តកម្ពុជា និងតំណែងរបស់ខ្លួនថាជា នាយករដ្ឋមន្ត្រី»* ។

**ក្រុមទី៥** ៖ តំណាងយុវជនម្នាក់នៅក្នុងក្រុមទី៥ បានឡើងមកខាងមុខវេទិកា រួចច្រៀងចំរៀងខ្មែរក្រហម ។ បន្ទាប់មកយុវជនម្នាក់ទៀតពន្យល់ពីអត្ថន័យនៃទង់ជាតិកម្ពុជាប្រជាធិបតេយ្យ និងសញ្ញាជាតិដែលបញ្ជាក់ពីសារសំខាន់នៃកសិកម្មនិងឧស្សាហកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

**ក្រុមទី៦** ៖ យុវជនតំណាងក្រុមទី៦ម្នាក់បានពន្យល់ដល់អ្នកចូលរួមទាំងអស់ពីប្រវត្តិរូបសង្ខេបរបស់ ខៀវ សំផន៖ «ខៀវ សំផន គឺជាមនុស្សដែលមានចំណេះដឹងម្នាក់



និងជាអ្នកដែលបានក្លាយទៅជាអ្នកកុម្មុយនីស្តនៅ អំឡុងឆ្នាំ១៩៦៧» ។ បន្ទាប់ពីក្រុមនីមួយឡើងសង្ខេបពីចំណុច របស់ខ្លួនរួចមក រ៉ាស៊ី បានធ្វើការសង្ខេបពីជំពូក៤ទាំងមូលដល់អ្នកចូលរួមឲ្យបានដឹងកាន់តែច្បាស់ ។ រ៉ាស៊ី បាន បន្តពីមួយចំណុចទៅមួយចំណុច ដើម្បីធ្វើឲ្យ កាន់តែច្បាស់ថាអ្នកចូលរួម ជាពិសេសយុវ ជនចាម ទទួលបានចំណេះដឹងពេញលេញពី ជំពូក និងរូបភាពដែលជាប់ទាក់ទងទៅនឹងរបប ខ្មែរក្រហម ។ បន្ទាប់ពីការធ្វើសេចក្តីសង្ខេបរបស់ រ៉ាស៊ី រួចមក បូលី បានចុះពីលើវេទិកាដើម្បីដឹកនាំកម្មវិធី សំណួរនិងចម្លើយ ។ ខាងក្រោមនេះគឺជាសំណួរដែលត្រូវបានសួរឡើងនៅក្នុងកម្មវិធីសំណួរនិងចម្លើយ៖

១) ហេតុអ្វីបានជាចាំបាច់ត្រូវតែកាត់ទោសមេដឹកនាំខ្មែរក្រហម?

*ចម្លើយ ៖ ខ្មែរក្រហមបានសម្លាប់មនុស្សអស់ជិតពីរលាននាក់ក្នុងចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩ ។ ឥឡូវនេះអស់រយៈពេលជិត៣០ឆ្នាំកន្លងមកហើយចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហម ប៉ុន្តែមេដឹកនាំនៃរបបនេះនៅតែត្រូវបានកាត់ទោស ។ យើងចង់ឃើញថាគ្មាននរណាម្នាក់គេចផុតពីច្បាប់បានឡើយ ។ ជនណាដែលបានប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម ត្រូវតែទទួលការកាត់ទោស ដើម្បីពង្រឹងនីតិច្បាប់ និងបញ្ចប់វប្បធម៌និទណ្ឌភាព (ការរួចទោស) ។ បន្ថែមពីនេះទៀត ការកាត់ទោសគឺជាការស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា ជាពិសេសចំពោះអ្នកដែលស្លាប់នៅក្នុងរបបខ្មែរក្រហម ។*

២) ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជន និងហេតុអ្វីបានជាប្រជាជនមិនតបតវិញ?

ចម្លើយ : ខ្មែរក្រហមជឿជាក់ថា កម្ពុជាចាប់តាំងពីការបង្កើតជាតិមក គឺមិនដែលមានភាពឯករាជ្យពេញលេញនៅឡើយទេ ។ ប្រជាជនកម្ពុជា ជាពិសេសប្រជាជនដែលរស់នៅតាមជនបទ គឺមិនដែលទទួលបានសិទ្ធិគ្រប់គ្រាន់ និងភាពជាម្ចាស់លើខ្លួនឯងឡើយ ។ អ្នកទាំងនោះជានិច្ចកាលត្រូវបានចាត់ទុកជាទាសករ ។ លើសពីនេះទៀត ខ្មែរក្រហមយល់ឃើញថាកម្ពុជាគឺជាជាតិមួយដែលពោរពេញទៅដោយអំពើពុករលួយ ការកេងប្រវ័ញ្ច និងអយុត្តិធម៌ ។ ទោះជាយ៉ាងនេះក៏ដោយ នៅពេលដែលខ្មែរក្រហមកាន់កាប់អំណាចនៅកម្ពុជា ពួកគេធ្វើបដិវត្តន៍ ដើម្បីនាំយុត្តិធម៌ជូនប្រជាជនកម្ពុជា ។ ដើម្បីអនុវត្តផែនការនេះ ខ្មែរក្រហមបានបណ្តេញប្រជាជនដែលរស់នៅក្នុងទីក្រុងទាំងអស់ឲ្យទៅរស់នៅតាមទីជនបទ ដើម្បីធ្វើស្រែចម្ការ ។ លក្ខណរស់នៅដែលមានផាសុខភាពដូចជារស់នៅក្នុងការិយាល័យដែលបំពាក់ទៅដោយម៉ាស៊ីនត្រជាក់ និងការហូបចុកនៅក្នុងភោជនីយដ្ឋានល្អៗ គឺមិនមានទៀតទេ ។ នរណាក៏ដោយ ត្រូវធ្វើការនៅក្នុងស្រែ ។ ផ្ទុយទៅវិញ អ្នកក្រត្រូវបានជ្រើសរើសឲ្យធ្វើជាប្រធានសហករណ៍ ប្រធានឃុំ ចៅហ្វាយស្រុក



និងធ្វើជាអ្នកចាត់ចែងកិច្ចការច្បាប់ផ្សេងៗទៀតនៅក្នុង ប្រទេស ។ ការផ្លាស់ប្តូរឆាប់រហ័ស បែបនេះបានឈានដល់ការ កាប់សម្លាប់មនុស្ស ។ បន្ថែមពី នេះទៀត ដើម្បីធ្វើឲ្យប្រទេសកម្ពុជាមានឯករាជ្យភាពពេញ លេញ ប្រជាជនកម្ពុជាទាំង អស់ត្រូវតែមានជំហរ និងឆន្ទៈ រឹងមាំ ។ មេដឹកនាំខ្មែរក្រហម ជឿជាក់ថា ប្រជាជនកម្ពុជា នៅទូទាំងប្រទេសមានតែថាមពល ប៉ុន្តែគ្មានជំហរបដិវត្តន៍ ដែលធ្វើឲ្យប្រទេសកម្ពុជាមិនអាចឈានទៅ រកភាពឯករាជ្យបានឡើយ ។ ទោះជាយ៉ានេះក្តី ខ្មែរក្រហមចង់ពង្រឹងគោលជំហរប្រជាជន ដោយបង្ខំប្រជាជនទាំងអស់ឲ្យធ្វើពលកម្មធ្ងន់ធ្ងរ ហូបតិច ខ្មែរក្រហមជឿជាក់ថា ធ្វើបែបនេះ ប្រជាជនគួរតែមានជំហរបដិវត្តន៍រឹងមាំ និងផ្លាស់ប្តូរប្រទេសឲ្យឆ្ពោះទៅរកសង្គមជាតិមួយដែលទំនើបបំផុតនៅក្នុងសាកលលោក ។ នរណាដែលមិនអាចគោរពតាម

គោលនយោបាយដ៏តឹងរ៉ឹងនេះ នឹងត្រូវបានចាត់ទុកជាសមាសភាពអាក្រក់ និងគួរតែត្រូវបោសសម្អាតចោល ។ ទាំងអស់នេះ គឺជាហេតុផលដែលមនុស្សប្រមាណពីរលាននាក់បានស្លាប់ក្នុងរបបខ្មែរក្រហម ។

ដើម្បីផ្តល់នូវឧទាហរណ៍ពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម ជាការឆ្លើយតបទៅនឹងសំណួររបស់យុវជនទាំងនោះ ក៏ដូចជាការផ្សារភ្ជាប់ទៅនឹងការពិភាក្សាទៅលើសៀវភៅប្រវត្តិសាស្ត្រទៅនឹងសហគមន៍ផងនោះ បូលី បានអញ្ជើញហាកិម ដែលជាអ្នកចាស់ទុំនិងជាអ្នកដឹកនាំសាសនាឥស្លាមនៅក្នុងស្រុកឆ្លូង ឲ្យឡើងបកស្រាយពីជីវិតរបស់គាត់ប្រាប់ដល់យុវជនទាំងអស់ ។ គាត់បាននិយាយថា ខ្លួនគាត់មានបទពិសោធន៍រៀនពីជីវិតរបស់គាត់ឆ្លងកាត់របបខ្មែរក្រហម ។ គាត់និយាយដូច្នេះថា "ខ្មែរក្រហមគឺឃោរឃៅខ្លាំងណាស់នៅក្នុងភូមិរបស់យើង ។ ពួកគេបានបង្ខំប្រជាជនទាំងអស់រួមទាំងក្មេងៗផង ឲ្យធ្វើការខ្លាំងហួសប្រមាណ ។ ពួកគេប្រើពាក្យ "សមមិត្ត" និង "អង្គការថ្នាក់លើ" ។ ខ្មែរក្រហមក៏បានបង្ខំមនុស្សវ័យចំណាស់ឲ្យធ្វើការងារដែរ ។ វាមានលក្ខណៈខុសគ្នានឹងសង្គមបច្ចុប្បន្នដែលយើងអាចដើរហើរសេរី ។ នៅពេលនោះ យើងមិនអាចដើរបានសេរីដូចសព្វថ្ងៃនេះទេ ។ ប្រសិនបើយើងដើរទៅកាន់ភូមិមួយទៀត យើងត្រូវតែទទួលទណ្ឌកម្ម ។ យើងមិនអាចស្លៀកពាក់ខោអាវពណ៌ចំរុះបានឡើយ ។ យើងមិនត្រូវបានអនុញ្ញាតិឲ្យទៅសួរសុខទុក្ខក្រុមគ្រួសារដែលឈឺបានឡើយ ។ បន្ទាប់ពីឆ្លងទន្លេរួចសម្រាប់រយៈពេលមួយខែ ម្តាយត្រូវតែត្រឡប់ទៅធ្វើស្រែវិញ ។ យើងត្រូវតែហូបបាយរួម ។

មិនមានការហូបចុកឯកជនឡើយ ។



ក្រុមគ្រួសារសាច់ញាតិចំនួន៤០នាក់របស់គាត់ ត្រូវបាននាំយកទៅ សម្លាប់ចោល ។

បន្ទាប់មក បូលី បានអញ្ជើញ នាយកសាលា លោក សេង ហឿន ឲ្យចែករំលែកបទពិសោធន៍របស់គាត់ជាមួយនឹងអ្នកចូលរួមទាំងអស់ ។ លោកនាយកបានមានប្រសាសន៍ថា "អនុវិទ្យាល័យពង្រ បានចាប់ផ្តើមបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ដល់សិស្សានុសិស្សកាលពីឆ្នាំមុន ។ ខ្ញុំសង្ឃឹមថាសិស្សានុសិស្សនឹងស្វែងយល់យ៉ាងហោចណាស់ពីទិដ្ឋភាពខ្លះៗនៃរបបខ្មែរក្រហមដែលបានសម្លាប់មនុស្សអស់យ៉ាងច្រើន ។ ខ្ញុំកើតនៅឆ្នាំ១៩៥៣ ដូច្នេះខ្ញុំពិតជាបានឆ្លងកាត់របបខ្មែរក្រហម ។ បន្ទាប់ពីឆ្នាំ

*១៩៧០មក ខេត្តក្រចេះគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ដោយបានស្តាប់ពុំសេចក្តីអំពាវនាវពីសំណាក់សម្តេចព្រះនរោត្តម សីហនុ ខ្ញុំបានរត់ចូលព្រៃជាមួយអ្នកភូមិឯទៀតដែរ ។ ខ្ញុំបានវិលត្រឡប់មកកាន់ស្រុកវិញនៅឆ្នាំ១៩៧៣ និងបានរៀបការ ។ ទោះជាការចូលបដិវត្តន៍តាំងពីឆ្នាំ១៩៧០មកក៏ដោយ ក៏ខ្ញុំនៅតែត្រូវបានដាប់ឈ្មោះជាបញ្ញវន្តដែលស្ថិតនៅក្នុងបញ្ជីខ្មៅរបស់ខ្មែរក្រហម ។ ទ្រព្យសម្បត្តិរបស់ខ្ញុំត្រូវបានប្រមូលផ្តុំ និងទុកនៅក្នុងសហករណ៍ ។ លើសពីនេះទៀត ខ្ញុំត្រូវបានបញ្ជាឲ្យបង្រៀនក្មេងៗនិងចាស់ៗ ។ មួយសន្ទុះក្រោយមក ខ្ញុំត្រូវបានដកចេញពីមុខងារជាគ្រូបង្រៀនឲ្យទៅធ្វើស្រែវិញ ។ ថ្ងៃមួយនៅក្នុងពេលប្រជុំ ខ្ញុំវិះនឹងស្លាប់ម្តងហើយ ។ ខ្ញុំត្រូវបានចោទប្រកាន់ពីបទបានស្តាប់វិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក និងត្រូវបានកត់សម្គាល់ថាជាខ្មាំង ។ ជាសំណាងល្អ ខ្ញុំត្រូវរួចផុតពីការសម្លាប់ដោយសារវត្តមានរបស់កងទ័ពវៀតណាមក្នុងខែមករា ។»*

បន្ទាប់មក បូលី បានអញ្ជើញតំណាងគ្រូម្នាក់ឈ្មោះ សារី ណាពីសាស់ ឲ្យធ្វើការចាប់អារម្មណ៍ចំពោះវេទិកានេះ ។ ណាពីសាស់ បាននិយាយថា នាងមានសេចក្តីរីករាយណាស់ដែលបានក្លាយជាផ្នែកមួយនៃការធ្វើវេទិកានេះ ព្រោះភូមិរបស់នាងមិនដែលបានរៀបចំវេទិការបៀបនេះពីមុនមកទេ ។ នាងកើតនៅក្រោយរបបខ្មែរក្រហម ។ ណាពីសាស់ មិនបានដឹងច្រើនអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមទេ ។ នាងជឿជាក់ថា អ្នកចូលរួមបានរៀនយ៉ាងច្រើនពីការធ្វើវេទិកាសាធារណៈនៅថ្ងៃនេះ ។ នាងស្នើសុំថា មជ្ឈមណ្ឌលឯកសារកម្ពុជាគួរនាំយកយុវជនចាមឲ្យទៅទស្សនាសារមន្ទីរទួលស្លែង និងវាលពិឃាតបឹងជើងឯកនៅក្នុងទីក្រុងភ្នំពេញ ដើម្បីយុវជនទាំងនោះបានឃើញពីទីតាំងប្រវត្តិសាស្ត្រទាំងនេះដោយផ្ទាល់ភ្នែក ។

នៅចុងបញ្ចប់នៃការធ្វើបទបង្ហាញ និងការពិភាក្សា សមាជិកក្រុមបានចែកតារាងស្ទាបស្ទង់មតិក្រោយការធ្វើវេទិកាសាធារណៈ ដើម្បីវាស់ស្ទង់ពីចំណេះដឹង ការចាប់អារម្មណ៍ និងការផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នកចូលរួមទាំងអស់ បន្ទាប់ពីបានចូលរួមនៅក្នុងវេទិកានេះរួច ។ នៅពេលរសៀលថ្ងៃដដែល សមាជិកក្រុមបានធ្វើកិច្ចសម្ភាសន៍ជាមួយនឹងយុវជនចាម អ្នកភូមិ និងគ្រូបង្រៀន ។



**យុវជនចាមកំពុងបំពេញតារាងស្ទាបស្ទង់មតិ**

## ទិន្នផល

វេទិកាសាធារណៈដើម្បីការអប់រំនេះ បានផ្តល់នូវចំណេះដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ជាពិសេសជំពូក៨នៃសៀវភៅប្រវត្តិសាស្ត្រ ដែលរៀបរាប់យ៉ាងគ្រោះក្បាយ ពីការបង្កើតរដ្ឋាភិបាល

កម្ពុជាប្រជាធិបតេយ្យ និងអ្នកដឹកនាំនៃរបបនេះ ទៅកាន់អ្នកចូលរួមចំនួនប្រហែល២៥០នាក់ ដែលរួមមានយុវជនចាម អ្នកភូមិ មេដឹកនាំសាសនាឥស្លាម គ្រូបង្រៀន និងអាជ្ញាធរមូលដ្ឋាន។ សមាជិកក្រុមការងារបានចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ចំនួន២០០ច្បាប់, ទស្សនាវដ្តីស្វែងរកការពិត ចំនួន២០០ច្បាប់, និងសៀវភៅនិយាយអំពីករណី០០១របស់ ឌុច និង០០២ ចំនួន២០០ច្បាប់ ដល់អ្នកចូលរួមទាំងអស់។ លើសពីនេះទៀត ក្រុមការងារបានធ្វើការសម្ភាសន៍មនុស្សចំនួន៧នាក់។

## លទ្ធផល

លោក សំ ឡារី ជានាយកសាលាសាសនាឥស្លាមនៅក្នុងសហគមន៍ចាម ដែលមាន៦ថ្នាក់ បាននិយាយថា គាត់មានសេចក្តីសប្បាយចិត្តជាខ្លាំងដែលបានឮថា ការប្រារព្ធធ្វើវេទិកាសាធារណៈដើម្បីការអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហម ត្រូវបានធ្វើឡើងនៅក្នុងវិហាររបស់គាត់។ នៅពេលដែលសិស្សសួរគាត់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម គាត់មិនមានមូលដ្ឋានច្បាស់ក្នុងការឆ្លើយតបទៅកាន់សិស្សវិញទេ ទោះជាគាត់ជាជនរងគ្រោះនៅក្នុងសម័យនោះក៏ដោយ។ សំណួរដែលគាត់ទទួលបានពីសិស្សរួមមាន៖ ហេតុអ្វីបានជារបបខ្មែរក្រហមសម្លាប់អ្នកចេះដឹង? ហេតុអ្វីបានជាខ្មែរក្រហមមិនអនុញ្ញាតិឲ្យជនជាតិចាមថ្វាយបង្គំ? តើខ្មែរក្រហមអភិវឌ្ឍប្រទេសជាតិតាមរបៀបយ៉ាងម៉េច ប្រសិនបើគេសម្លាប់ប្រជាជនបែបនេះ? តើវាសនារបស់ប្រជាជន និងវិហាររបស់ចាមនៅក្នុងរបបខ្មែរក្រហម ទៅជាយ៉ាងណា?



លោក សំ ឡារី មិនដឹងឆ្លើយតបទៅនឹងសំណួរទាំងនេះដោយរបៀបណាទេ។ ក្រោយពីបានស្តាប់ការពិភាក្សានៅក្នុងវេទិកានេះរួចមក គាត់បានរំពឹកថា វិហារឥស្លាមត្រូវបានប្រើប្រាស់ធ្វើជាទ្រុងជ្រូកក្នុងរបបខ្មែរក្រហម។ លោក ឡារី បាននិយាយបន្តថា គាត់បានស្វែងយល់ច្រើនណាស់បន្ទាប់ពីបានចូលរួមនៅក្នុងវេទិកានេះ។ គាត់បានសួររកពីព័ត៌មានសម្រាប់ទំនាក់ទំនងទៅថ្ងៃក្រោយ ក្នុងករណីដែលគាត់ចង់សួរសំណួរមួយចំនួនទៀតដែលគាត់មិនអាចឆ្លើយតបទៅនឹងសំណួរភ្លាមៗបាន។ គាត់បាននិយាយថា សៀវភៅប្រវត្តិសាស្ត្រនេះគឺជាក្បួនខ្នាតសម្រាប់គាត់។ គាត់នឹងយោងទៅលើសៀវភៅប្រវត្តិសាស្ត្រ នៅពេលដែលគាត់ជួបនឹងសំណួរដែលទាក់ទងទៅនឹងរបបខ្មែរក្រហម។

សមាជិកក្រុមការងារបានលើកទឹកចិត្តគ្រូបង្រៀន និងមេដឹកនាំសហគមន៍ចាមឲ្យប្រើប្រាស់គោលការ

សិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនសិស្សទាំងក្នុងនិងក្រៅថ្នាក់រៀន ក៏ដូចជាសិស្សនៅក្នុងក្រុមតូចនិងក្រុមធំដែរ ។ ការពិភាក្សាជាមួយគ្រូបង្រៀន និងមេដឹកនាំសហគមន៍ បានបង្ហាញឲ្យឃើញថា យុវជនចាមមានការអៀនខ្មាស់បន្តិចបន្តួច និងត្រូវការលើកទឹកចិត្តឲ្យនិយាយនិងអនុវត្តនៅក្នុងស្ថានភាពខុសៗគ្នា ។ មេដឹកនាំទាំងនោះបាននិយាយថា គាត់ចង់ឲ្យក្មេងៗជំនាន់ក្រោយរបស់គាត់ក្លាយជាអ្នកក្លាហាន និងមានលទ្ធភាពនិយាយនៅក្នុងក្រុមធំ ដែលវាសំខាន់ណាស់សម្រាប់ការងារ និងជីវិតទៅថ្ងៃអនាគតរបស់ខ្លួន ។ ឃើញសភាពបែបនេះ សមាជិកក្រុមបានកាត់បន្ថយការនិយាយរបស់ខ្លួន ដោយលើកទឹកចិត្តឲ្យក្មេងៗជំនាន់ក្រោយធ្វើការពិភាក្សា និងសួរសំណួរ ។ សមាជិកក្រុមការងារបានធ្វើយ៉ាងល្អក្នុងការផ្តល់ឱកាសឲ្យក្មេងជំនាន់ក្រោយឡើងមកខាងមុខវេទិកាដើម្បីសួរសំណួរ និងធ្វើការសង្ខេបពីអ្វីដែលខ្លួនបានរៀនកន្លងមក ។ បន្ទាប់មកទៀត សមាជិកក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានពន្យល់ពីសារសំខាន់នៃសកម្មភាពក្លាហានទាំងនេះថា ជាទម្លាប់ល្អសម្រាប់វិជ្ជាជីវៈរបស់ខ្លួននាពេលអនាគត ។ ក្រុមការងារបានពន្យល់ថា «នៅពេលដែលអ្នកក្លាយជាអ្នកដឹកនាំ អ្នកត្រូវតែនិយាយ និងមានលទ្ធភាពរិះគិតពីគំនិតផ្ទាល់ខ្លួន» ។ នៅចុងបញ្ចប់ ក្រុមការងារធ្វើការបូកសរុប ដោយលើកទឹកចិត្តគ្រូបង្រៀនឲ្យបង្កើតការត្រិះរិះពិចារណានិងការសិក្សាដោយខ្លួនឯងចំពោះក្មេងទាំងអស់ ដោយផ្តល់ឲ្យអ្នកទាំងនោះនូវឱកាសក្លាយទៅជាអ្នកសិក្សាយ៉ាងសកម្ម ។ ក្មេងៗត្រូវការរៀនសូត្រពីអ្វីដែលធ្វើឲ្យខ្លួនឯងនឹងក្លាយជាអ្នកឯករាជ្យ និងអ្នកទទួលខុសត្រូវចំពោះកិច្ចការនិងសកម្មភាពរបស់ខ្លួន ។

## ផលប៉ះពាល់



គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតវគ្គបណ្តុះបណ្តាលគ្រូនៅក្នុងទូទាំងប្រទេស ។ ប្រធានគណៈកម្មការយុវជនឥស្លាមប្រចាំស្រុកឆ្លូង លោក សា សូពៀត បានស្នើសុំថា គ្រូបង្រៀនក្នុងសហគមន៍ចាម គួរតែត្រូវបានចូលរៀននៅក្នុងវគ្គបណ្តុះបណ្តាលនេះដូចគ្រូឯទៀតដែរ ។ សូពៀត បានប្រាប់ ថា ចំនួនក្មេងៗជនជាតិចាមភាគច្រើនបានឈប់រៀននៅសាលារដ្ឋជារៀងរាល់ឆ្នាំ ដោយសារភាពក្រីក្រ ។ ក្មេងទាំងនោះត្រូវតែមានឱកាសរៀនពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលជាផ្នែកមួយសំខាន់ទាក់ទងទៅនឹងអត្តសញ្ញាណរបស់ខ្លួន និងការកសាងសហគមន៍ចាមឡើងវិញ បន្ទាប់ពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ ទោះជាក្មេងៗឥស្លាមឈប់រៀននៅក្នុងសាលារដ្ឋក៏ដោយ ក៏អ្នកទាំងនោះបានចូលរៀននៅក្នុងសាលាសាសនា ជាទី

កន្លែងដែលខ្លួនបានរៀនពីក្បួនច្បាប់ សាសនា គោលការណ៍សាសនា និងចំណេះដឹងសង្គមដទៃទៀត ។ លោក សូពៀត មានជំនឿថា ក្នុងករណីដែល ទូនមួយចំនួនមានឱកាសបានទៅចូលរួមវគ្គបណ្តុះបណ្តាលគ្រូ ក្មេងៗជំនាន់ក្រោយរបស់សហគមន៍ចាម នឹងមានលទ្ធភាពចាប់យកនិងយល់ដឹងអំពីការឈឺចាប់របស់ជនជាតិចាមនៅក្នុងរបបខ្មែរក្រហម ។

លោក សេង ហឿន ជានាយកអនុវិទ្យាល័យពង្រ បានបញ្ជាក់ថា គាត់បានអនុញ្ញាតិឲ្យគ្រូបង្រៀនម្នាក់បង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងម៉ោងប្រវត្តិវិទ្យានៅក្នុងសាលារបស់គាត់កាលពីឆ្នាំកន្លងទៅ ។ លោក នង សារ៉ុម ជាគ្រូបង្រៀននៅអនុវិទ្យាល័យពង្រ គឺជាគ្រូតែម្នាក់គត់ដែលតំណាងឲ្យគ្រូបង្រៀនប្រវត្តិវិទ្យានៅក្នុងស្រុកឆ្លូង ដែលត្រូវបានជ្រើសរើសឲ្យទៅចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលគ្រូខ្ទេសថ្នាក់ខេត្ត ។ បន្ទាប់ពីបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលគ្រូខ្ទេសថ្នាក់ខេត្ត និងបានចូលរួមជាអ្នកបណ្តុះបណ្តាលនៅក្នុងវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានរួចមក លោកគ្រូ នង សារ៉ុម បានចែករំលែកសៀវភៅណែនាំគ្រូ និងសម្ភារៈដទៃទៀតដែលគាត់បានទទួលពីវគ្គបណ្តុះបណ្តាល ទៅឲ្យគ្រូផ្សេងទៀតនៅក្នុងសាលារបស់គាត់ ។ លោកនាយកអនុវិទ្យាល័យបាននិយាយថា គាត់មិនទាន់បានទទួលការណែនាំថ្មីពីក្រសួងអប់រំ យុវជន និងកីឡា ឬពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តក្រចេះ នៅឡើយទេនៅក្នុងឆ្នាំនេះ ស្តីពីការដាក់បញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងម៉ោងប្រវត្តិវិទ្យា ។ ការណ៍នេះបញ្ជាក់ពីភាពចន្លោះប្រហោងក្នុងការធ្វើទំនាក់ទំនង និងបែងចែកព័ត៌មានអំពីការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមវិទ្យាល័យក្នុងទូទាំងប្រទេស ។ មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវតែរំឭកក្រសួងអប់រំ យុវជន និងកីឡា និងស្នើថាគ្រប់វិទ្យាល័យទាំងអស់គួរតែទទួលបានលិខិតដែលចេញដោយក្រសួង អំពីការប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រនៅក្នុងថ្នាក់រៀន ចាប់តាំងពីសៀវភៅនេះបានទទួលការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា ថាចាំបាច់សម្រាប់មុខវិជ្ជាប្រវត្តិវិទ្យា អក្សរសាស្ត្រខ្មែរ និងសីលធម៌ពលរដ្ឋតាំងពីឆ្នាំ២០០៨ ។ ការយល់ព្រមនេះ ផ្តល់ឱកាសឲ្យគ្រូបង្រៀនប្រើប្រាស់សៀវភៅនេះដើម្បីបង្រៀនសិស្ស ។

បញ្ហាប្រឈមចំពោះការអនុវត្តន៍ការបង្រៀនសៀវភៅប្រវត្តិសាស្ត្រនេះ គឺកំពុងតែដាក់បញ្ចូលសេចក្តីណែនាំពីវិធីសាស្ត្របង្រៀនដែលជាកិច្ចការមួយថ្មីសម្រាប់មន្ត្រីរបស់ក្រសួង និងគ្រូបង្រៀនដែលជាអ្នកអនុវត្តវិធីសាស្ត្រ ក្បួនខ្នាត និង កិច្ចការរដ្ឋបាលដែលមានពីមុនមក ។ ដើម្បីឲ្យមានការប្រើប្រាស់កម្មវិធីសិក្សាដោយសេរី ទាំងមន្ត្រី និងគ្រូបង្រៀនចង់ឃើញសៀវភៅប្រវត្តិសាស្ត្រនេះត្រូវបានកត់ចូលក្នុងបញ្ជីដូចគ្នានឹងសៀវភៅសិក្សាដទៃទៀតដែលក្រសួងអប់រំ យុវជន និងកីឡាផ្តល់សិទ្ធិសម្រាប់ការប្រើប្រាស់នៅក្នុងសាលារៀន ។ បញ្ហាប្រឈមមួយផ្សេងទៀត គឺថាគ្រូបង្រៀនក្នុងទូទាំងប្រទេសមិនមានពេលវេលាគ្រប់គ្រាន់ក្នុងឆ្នាំមូលដ្ឋានដើម្បីបង្រៀនពីអ្វីដែលថ្មីឡើយ ។ ទោះជាយ៉ាងនេះក៏ដោយ គ្រូបង្រៀនមិនមានការលើកទឹកចិត្ត និងពេលវេលាគ្រប់គ្រាន់ក្នុងការប្រើប្រាស់កម្មវិធីបន្ថែមថ្មីៗបានឡើយ ទោះបីជាគាត់មើលឃើញថាសម្ភារៈដែលទទួល

ទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានប្រយោជន៍និងផលចំណេញសម្រាប់សិស្សក៏ដោយ ។

ដើម្បីជាការលើកទឹកចិត្តដល់យុវជនចាមឲ្យសិក្សានៅក្នុងសាលារៀន និងបន្តការសិក្សារបស់ខ្លួនឡើងវិញ បូលី បានប្រាប់សិស្សទាំងអស់ឲ្យយកកញ្ញា សូ ហារីណា ធ្វើជាគំរូ និងជាប្រភពនៃគំនិតសម្រាប់យុវជនចាមទូទៅ ។ បូលី បាននិយាយទៀតថា កញ្ញា ហារីណា ក៏ជាអ្នកដែលកើតចេញពីគ្រួកូលអ្នកក្រីក្រដែរ ។ នាងបានរៀបចំការរៀនសូត្ររបស់នាង និងមានលទ្ធភាពទទួលបានសញ្ញាបត្រអនុបណ្ឌិតមកពីសហរដ្ឋអាមេរិក ។ ដោយសារការប្តេជ្ញាចិត្តរបស់នាងសម្រាប់ភាពជោគជ័យ ទើបពេលបច្ចុប្បន្ននេះ ហារីណា កំពុងតែដឹកនាំគម្រោងមួយដែលធ្វើការជាមួយវិហារឥស្លាមចំនួនជាង៣០០ក្នុងប្រទេសកម្ពុជា ដើម្បីជួយដល់សហគមន៍ចាមក្នុងការពង្រឹងសុខមាលភាព និងដើម្បីថែរក្សាអត្តសញ្ញាណរបស់ខ្លួន ។ ដូច្នេះ យុវជនចាមបានស្នើសុំឲ្យ កញ្ញា ហារីណា មកកាន់ភូមិរបស់ខ្លួនដើម្បីចែករំលែកកិច្ចការ និងបទពិសោធន៍ពីការសិក្សារបស់នាងដល់សហគមន៍ ។ នៅក្នុងគម្រោងរបស់ ហារីណា យុវជនទាំងអស់ចង់ទៅធ្វើទស្សនកិច្ចនៅសារមន្ទីរឧក្រិដ្ឋកម្មទួលស្លែង និងវាលពិឃាតបឹងជើងឯក ដែលជាផ្នែកមួយនៃការសិក្សារបស់ខ្លួនដើម្បីកសាងចំណេះដឹងក្នុងសហគមន៍ ។

## បញ្ហាប្រឈម និងការផ្តល់អនុសាសន៍

អ្នកចូលរួមនៅក្នុងវេទិកា ហាក់ចាប់អារម្មណ៍ច្រើនក្នុងការសួរសំណួរបន្ទាប់ពីការធ្វើបទបង្ហាញទៅលើជំពូកនៃសៀវភៅប្រវត្តិសាស្ត្រ ជាជាងការស្តាប់ទៅលើការបង្រៀនពេញម៉ោង ។ វាគឺជាបញ្ហាក្នុងការទាញយកការចាប់អារម្មណ៍របស់អ្នកចូលរួមចំពោះថេរវេលាដ៏អស្ចារ្យ ។ អ្នកធ្វើបទបង្ហាញ ត្រូវតែធ្វើយ៉ាងណាឲ្យការធ្វើសេចក្តីសង្ខេបតាមក្រុមនីមួយៗរបស់អ្នកចូលរួម មានរយៈពេលខ្លីបន្តិច ជាក់លាក់ និងជាប់ទាក់ទងគ្នា ។ អ្នកធ្វើបទបង្ហាញ ត្រូវតែដឹងពីអារម្មណ៍របស់អ្នកស្តាប់និងអ្នកដែលនៅជុំវិញខ្លួន ព្រមទាំងធ្វើយ៉ាងណាឲ្យយល់ពីតម្រូវការរបស់អ្នកចូលរួម ។

ដើម្បីជួយសម្រួលដល់ការអស់កម្លាំងរបស់អ្នកចូលរួមដែលអង្គុយរហូតដល់ជាងបីម៉ោង គ្រប់ការធ្វើវេទិកាសាធារណៈគួរតែមានអ្នកធ្វើបទបង្ហាញលើសពីពីរនាក់ ។ អ្នកចូលរួមអាចបាត់បង់ការចាប់អារម្មណ៍ប្រសិនបើអ្នកទាំងនោះស្តាប់អ្នកធ្វើបទបង្ហាញតែម្នាក់ ឬពីរនាក់នៅក្នុងរយៈពេលពីបីទៅបួនម៉ោង ។ នៅក្នុងការធ្វើវេទិកាសាធារណៈលើកនេះ បូលី និង រ៉ាស៊ី បានចែកវេនគ្នាដឹកនាំការពិភាក្សាជាមួយអ្នកចូលរួមទាំងអស់ ។ បន្ថែមពីនេះទៀត បូលី បានអញ្ជើញហាគីម និងនាយកសាលាឲ្យចែករំលែកប្រវត្តិផ្ទាល់ខ្លួនរបស់គាត់ និងពិភាក្សាពីវាសនាសហគមន៍ចាមក្នុងរបបខ្មែរក្រហមដល់អ្នកចូលរួមស្តាប់ ។ ជាលទ្ធផលនៃការស្តាប់វាគ្មិនអ្នកចូលរួមទាំងអស់បានទទួលព័ត៌មានខុសៗគ្នាពីប្រធានបទតែមួយ និងអាចភ្ជាប់ការពិភាក្សានៅក្នុងសៀវភៅប្រវត្តិសាស្ត្រទៅនឹងប្រវត្តិរបស់សហគមន៍របស់គាត់ ។

ដោយផ្អែកទៅលើការធ្វើវេទិកាដែលបានប្រារព្ធធ្វើឡើងដូច្នេះ ក្រុមការងារបានស្វែងយល់ថា បញ្ហានៃការធ្វើវេទិកានេះគឺមានកម្មវិធីច្រើនពេក ហើយដែលគួរតែកាត់បន្ថយខ្លះ ។ ក្រុមការងារត្រូវតែរក្សានូវ

គោលបំណងឲ្យនៅដដែល ដោយទុកឱកាសអ្នកចូលរួមនិយាយនិងចែករំលែកបទពិសោធន៍របស់គាត់ជាមួយនឹងក្មេងៗជំនាន់ក្រោយ នៅក្នុងការរៀបចំការពិភាក្សាជាសាធារណៈ ។ វេទិកាសាធារណៈ គួរផ្ដល់ឱកាសដល់អ្នកចូលរួម ជាពិសេសក្មេងៗជំនាន់ក្រោយឲ្យពិភាក្សាពីមាតិកានៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ដោយតភ្ជាប់ការពិភាក្សានេះទៅនឹងប្រវត្តិសហគមន៍របស់ខ្លួន ។ ទោះជាយ៉ាងនេះក៏ដោយ ក្រុមការងារគួរតែសង្ខេបឲ្យខ្លីនូវសកម្មភាពមួយចំនួន ដូចជាការធ្វើបទបង្ហាញពីការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គម្រោងនិងការសង្ខេបពីជំពូកនៅក្នុងសៀវភៅមេរៀន ។ អ្នកធ្វើបទបង្ហាញត្រូវតែរៀបចំពេលវេលាឲ្យបានត្រឹមត្រូវ ។ ការធ្វើបទបង្ហាញអំពីកិច្ចការរដ្ឋបាលទូទៅ គួរតែត្រូវធ្វើឡើងមិនឲ្យលើសពីរយៈពេលប្រាំនាទីឡើយ ។ ក្រុមការងារគួរតែទុកពេលវេលាច្រើនសម្រាប់ការពិភាក្សា និងសំណួរចម្លើយដែលនឹងទទួលបានផលប្រយោជន៍ច្រើន ។ វាក៏ជាគំនិតដ៏ប្រសើរមួយក្នុងការបង្កើតឲ្យមានពេលសម្រាករយៈពេលខ្លី ឬបង្កើតឲ្យមានសកម្មភាពធ្វើលំហាត់ដើម្បីឈានទៅកាន់ដំណាក់កាលមួយផ្សេងទៀត ។

ក្នុងការធ្វើវេទិកាសាធារណៈលើកនេះ មានអ្នកភូមិនិងគ្រូបង្រៀនតិចតួចប៉ុណ្ណោះដែលបានមកចូលរួម និងពុំសូវមានការពិភាក្សាអ្វីច្រើនពេកទេរវាងក្មេងៗជំនាន់ក្រោយនិងចាស់ទុំរបស់ពួកគេ ។ ការពិភាក្សានេះគឺមិនសូវស៊ីសង្វាក់គ្នានៅក្នុងចំណោមយុវជនចាមឡើយ ។ វេទិកានេះមានបំណងចង់ធ្វើឲ្យមានការជាប់ទាក់ទងគ្នារវាងមនុស្សបីប្រភេទគឺ សិស្ស ឪពុកម្ដាយសិស្ស និងគ្រូបង្រៀន ។ ដូច្នេះ វាគួរតែជាមានការពិភាក្សាគ្នាយ៉ាងច្បាស់លាស់មួយជាមួយនឹងមេដឹកនាំសហគមន៍ក្នុងការអញ្ជើញអ្នកចូលរួមមកពីក្រុមផ្សេងគ្នាដើម្បីចូលរួមនៅក្នុងវេទិកានេះ ។

**ខាងក្រោមនេះជាបទសម្ភាសន៍រវាង ឌី ខាំបូលី ជាមួយយាយម យី ភេទស្រី អាយុ៧៨ឆ្នាំ រស់នៅភូមិពង្រ២ ឃុំពង្រ ស្រុកត្បូង ខេត្តក្រចេះ។**

**យី** : យប់ហ្នឹងម៉ោង៦ ភ្លឺគាត់ខូច ។

**បូលី**: គាត់ខូចនាសម័យខ្មែរក្រហមទេចុះ?

**យី** : ចាំ! គេកៀរគាត់កាលពីគាត់ជិតដាច់ហើយហ្នឹង កុំអីខ្ញុំមិនដឹងថាកាយដឹកប់នៅកន្លែងណាទេ បើកុំយកគាត់ឡើងមក ចុះបានថាសំណាងគាត់ល្អណាស់ ។ មកដល់ផ្ទះម៉ែខ្ញុំហ្នឹង បានមានទៀន មានធូប មានចាស់ទុំអី មានក្ដារ ម៉ែក្មេកថាចនេះ គាស់ក្ដារជញ្ជាំងគាត់ គាត់គាស់ក្ដារហ្នឹងយកមកធ្វើក្ដារកាក់ម៉ាយើងហ្នឹង ដាក់នៅឯភូមិម៉ែខ្ញុំហ្នឹងទៅ ។

**បូលី**: ចុះគាត់ស្លាប់យូរហើយចឹងហ្ន៎?

យី ៖ តាំងពីដាច់ មិនទាន់សន្តិភាពស្រុកហ្នឹងស្រួលបួលផង ទុកនៅហ្នឹងទៅ រួចយើងទុកដាក់ ឲ្យគាត់រួចទៅ ក៏បានមកស្រុកខ្លះអីខ្លះចុឹងដែរទេ ដូចថាវាចង់ដាច់ហើយ ចង់ឈប់ហើយ បន្ទាប់មកបានប៉ុន្មានខួបក៏ទៅលើកគាត់យកមក ។

ចូលី ៖ចុឹងខ្មែរក្រហមកាន់កាប់ហ្នឹងយូរហើយហ្ន៎យាយ មុន៧៩ ទៀតណ៎យាយ? តាំងពីជំនាន់ពួកជីវគី?

យី ៖ អាហ្នឹងវាមួយសារ ពីរសារហើយ ។

ចូលី ៖ បាទ!

យី ៖ ពីរ បីសារហើយ បានមកធូន់ត្រង់ជំនាន់ប៉ុលពត ធូន់ហ្នឹងហើយបានយើងខ្វាត់ព្រាត់ទៅហ្នឹង ។ ទុកដាក់ម៉ាអីរួចនន ហើយនឹងខាល់ទៅ ។ ខាល់ជាទ័ពចល័ត មិនទាន់ទៅដល់ ផ្ទះឯណា ។

ចូលី៖ គាត់ពីនាក់ហ្នឹងដើរទៅ?

យី ៖ ចា៎! នៅតាមភូមិគេផ្ទះគេ ដឹងដំណឹងថាម៉ាខូច ទុកដាក់អីរួចវាទៅដល់ ។

ចូលី៖ កាលហ្នឹងទៅដល់មានប៉ុន្មាននាក់? មានអ៊ឹនន អ៊ឹខាល់ យាយ តា?

យី ៖ តែពីរនាក់ហ្នឹង វាដើរកងចល័យ ពួកខ្ញុំទាំងអស់គ្នា ទាំងអ៊ឹប្រុស អ៊ឹស្រី កុង ម៉ានៅ ខូចនៅផ្ទះម៉ែខ្ញុំទៅ ។ នេះជាបុណ្យគាត់ហើយ បើកាលហ្នឹងគាត់ខូចនៅបឹងរីង មិនដឹង ជាធ្វើម៉េចទេ ។

ចូលី៖ យាយម្នាក់ឯងទេហ្ន៎ដែលយកគាត់ទៅ?

យី ៖ ទាំងអស់គ្នា ប៉ុន្តែខ្ញុំបរទេះពីផ្ទះម៉ែខ្ញុំទៅយកគាត់មកភូមិមកផ្ទះគាត់វិញហ្នឹងណា ។ ហើយផ្ទះខ្ញុំ ប្អូនខ្ញុំនៅជាប់បន្ទាយគ្រាប់ហ្នឹងទៀត ។ យកទៅដាក់ផ្ទះម៉ែដាត ដាតទៅរៀនកាលហ្នឹងណ៎ ដាតដែលពស់ខាំជើង ។ យកទៅដាក់ហ្នឹង គាត់ខូចនៅហ្នឹងស្រួលបួល បងប្អូនជួយជ្រោមជ្រែក ក្មួយគេធ្វើខាងពាណិជ្ជ ធ្វើក្តារធ្វើអី ឲ្យដែកគោល ។ ហ្នឹងនឹក សំណាងបុណ្យម៉ាខ្ញុំ បើកុំមកខូចហ្នឹងមិនដឹងជាពិបាកយ៉ាងម៉េចទេ ដូចបឹងរី អន្លង់ សាឡីអី យើងទៅរកអីឯណា ។

ចូលី៖ គាត់អាយុប្រហែលប៉ុន្មានពេលគាត់ខូច?

យី ៖ ម៉ាយើងហ្នឹងហ្ន៎?

ចូលី៖ បាទ!

យី ៖ ៨០ជាងហើយ តែមិនដឹង៨០ ប៉ុន្មាន ។

ចូលី៖ ម៉ាបូ?

យី ៖ ចា៎!

ចូលី៖ អាយុច្រើនណាស់ហ្ន៎!

យី ៖ បើកុងយើងច្រើនណាស់ហើយអាយុ ។

ចូលី៖ គាត់ខូចដោយសារអីយាយកាលហ្នឹង?

យី ៖ គាត់ខូចក្រុនតិចតួច បីបួនថ្ងៃ ប៉ុណ្ណឹងតើម៉ា ។

ប៊ូលី៖ អត់ឈឺអីសោះ?

យី ៖ អត់មានឈឺអីទេ ទៅពីផ្ទះហ្នឹងគាត់ដើរទេ ហើយគាត់ទៅដេកនៅវត្តព្រែកសំរោង កន្លែងកំពង់កាណូត ប៉ុន្មានហ្នឹងមួយយប់គាត់ក្តៅហ្នឹង រួចមេក្រូចេះតែស្រែឲ្យចុះ ឲ្យចុះ គាត់ស្ទន់នឹងសំលេងហ្នឹង គាត់ទៅសម្រាកនៅហ្នឹងពីរយប់ក៏មិនដឹង បីយប់ក៏មិនដឹង រួចបាននាំគាត់ឡើងមកវិញហ្នឹងណា តែវាអត់ឲ្យមកទេ ប៉ុន្តែចេះតែបណ្តាក់ៗ ។

ប៊ូលី៖ ចុះកាលពីគេមកស្រែឲ្យចុះពីកំពង់ហ្នឹងឆ្នាំណា?

យី ៖ ៧៩ ។

ប៊ូលី៖ ចុឹងសម័យខ្មែរក្រហមយាយនៅហ្នឹងទាំងអស់គ្នា?

យី ៖ នៅទាំងអស់គ្នា ។

ប៊ូលី៖ ចុឹងដែលថាដេញចេញហ្នឹង៧៩ទេ ។

យី ៖ ៧៩! វាចង់ដាច់ហើយហ្នឹង ។

ប៊ូលី៖ បាទ! ចុះឆ្នាំ៧៥ ដល់៧៩ ហ្នឹងអត់មានគេជម្លៀសទៅណាទេចុឹង?

យី ៖ អត់ទេ ។

ប៊ូលី៖ គេឲ្យនៅហ្នឹង?

យី ៖ ឲ្យនៅ បើថាខុសពីយើងចាមទៅផ្ទះខ្មែរ ខ្មែរទៅផ្ទះចាម ចាមមកនៅផ្ទះខ្មែររហូតចុឹង ។ តែគ្រួសារយើងនៅផ្ទះយើងទាំងអស់ អត់អីដែរ ។

ប៊ូលី៖ មូលហេតុអ្វីបានយើងអាចនៅផ្ទះយើងបាន?

យី ៖ អត់ដឹងដែរ ។

ប៊ូលី៖ យើងមានអ្នកណាធ្វើកម្មាភិបាលខ្មែរក្រហមអីអត់?

យី ៖ អត់មានទេ ។ ប៉ុន្តែអ៊ំឡូ គេជម្លៀស ។ អ៊ំឡូគេជម្លៀសទៅភូមិចាម ។

ប៊ូលី៖ ភូមិណា?

យី ៖ ភូមិខាងលិច ភូមិចាម ផុតតែពីយើងផ្ទះពីរ បីជ្រកហ្នឹងទៅចាមហើយ ។

ប៊ូលី៖ ចុឹងជិតហ្នឹងដែរហ្នឹងចុឹង!

យី ៖ ចា៎! ជិតហ្នឹង ។ អ៊ំឡូអត់ទាន់មានផ្ទះនេះទេណា៎ អត់ទាន់ធ្វើទេ គាត់នៅខាងមុខ ។ ផុតពីគ្រាប់មកគាត់ធ្វើផ្ទះទាមនៅមុខ ខ្ញុំនៅតែផ្ទះខ្ញុំដដែលទេ ។ គាត់ថែកុង ខ្ញុំថែម៉ា ។

ប៊ូលី៖ កុងនៅជាមួយគាត់?

យី ៖ ចា៎! ថៃមួយម្នាក់ៗ ហើយបានអាថាចខ្ញុំនោះ ទៅធ្វើកងចល័តរកត្រីរកអីមកយកដាក់ តាមជើងខោខ្លាចគេណា៎ យកមកចិញ្ចឹមជីដូនជីតា ស្ងួអីចឹងទៅ គេឲ្យស៊ីបាយតាមរោង រួចយើងអត់ឲ្យគាត់ពិសារនៅហ្នឹង យកមកអាំងប្រលាក់អីទៅៗ បានពីនេះ បញ្ចូននៅនោះ បានពីនោះបញ្ចូនមកនេះកំពង់ចាមៗ

ប៊ូលី៖ ហើយខ្មែរក្រហមគេអត់ថាអីដែរហ្ន៎?

យី ៖ គេអត់ឃើញ គេអត់ដឹងទេៗ

ប៊ូលី៖ យើងលួយលាក់?

យី ៖ យើងលួចលាក់ណាស់ៗ បើទៅទាញអួននៅកោះអីយកមកហើយៗ

ប៊ូលី៖ ទាញអួនឲ្យខ្មែរក្រហមហ្នឹងហ៎?

យី ៖ ចា៎!

ប៊ូលី៖ ហើយយើងលួចដាក់ជើងខោយកមក?

យី ៖ ហ្នឹងហើយ! ជួនណាក៏វេចនឹងក្រមាហើយយកមក រុំនឹងក្បាលយកមកឲ្យ ចិញ្ចឹមជីដូន ហើយអានេះគេខាងភស្តុភា ស្ករអីហ្នឹងហើយ ចេះតែលួយគេតិចៗយកមកចិញ្ចឹមជីដូន ជីតាៗ

ប៊ូលី៖ អ្នកណា?

យី ៖ ខាក់ហ្នឹងណា!

ប៊ូលី៖ ខាក់ខាងភស្តុភា?

យី ៖ ចា៎! បើនៅលោកក៏គេផ្សឹកហ៎ៗ ផ្សឹកមកក៏គេឲ្យនៅខាងភស្តុភាហ្នឹងទៅៗ

ប៊ូលី៖ ប្រហែលយើងប្រជាជនចាស់ គេមិនសូវធ្វើបាបយើងដែរៗ

យី ៖ អត់អីដែរៗ

ប៊ូលី៖ ហើយហូបចុកអីម៉េចដែរយាយ? បានបាយ ឬក៏បបរ?

យី ៖ បបររាវៗ

ប៊ូលី៖ ហូបរួម ឬក៏ហូបតាមផ្ទះ?

យី ៖ ហូបរួម ប៉ុន្តែម៉ាយើងគេឲ្យហូបផ្ទះៗ ម៉ាយើងគេដួសដាក់កាតូឲ្យទៅណា ចាស់ម៉ា ហើយនឹងកុនៗ ហើយយើងចេះតែរកកែវផ្អុកឲ្យគាត់ពិសារៗ ទៅស្ទូង ទៅដកអីហ្នឹង រកត្រី ហើយចេះដាក់មង បានមកវេចក្រមាមក យកមកធ្វើអីៗឲ្យគាត់ពិសារៗ

ប៊ូលី៖ កាលហ្នឹងនៅប៉ុន្មានគ្រួសារនៅនេះយាយ គ្រួសារយាយមួយ គ្រួសារយាយឡូមួយ?

យី ៖ ចា៎! តែពីរហ្នឹងៗ

ប៊ូលី៖ តែពីរហ្នឹងទេចឹង? បើយាយឡូម យាយវឿនទៅនៅនោះអស់ហើយ?

យី ៖ ទៅនៅនោះអស់ហើយ ។

ប៊ូលី៖ ហើយមានបានទាក់ទងគ្នាអត់នៅអំឡុងពេល ៧៥ ដល់៧៩ហ្នឹង?

យី ៖ អត់ទេ អត់មានបានទៅមកផង ។

ប៊ូលី៖ ដាច់តែម្ដង?

យី ៖ ដាច់! ប៉ុន្តែម៉ា កុងនៅនេះទាំងអស់ កុងយកទៅលិច ។ ប៉ុន្តែយើងលាក់លួចចេះតែនៅ រាល់ថ្ងៃទៅណា ។

ប៊ូលី៖ ពេលដែលយើងទៅមកៗហ្នឹង យើងមានសុំការអនុញ្ញាតពីគេអត់?

យី ៖ អត់ទេ ។

ប៊ូលី៖ លួច?

យី ៖ លួច!

ប៊ូលី៖ ទៅពេលណា?

យី ៖ បានពេលណាទៅពេលហ្នឹង ។ ជិតដែរណា៎! ទៅលេងចិុងទៅបានអីលាក់ៗដាក់ហោប៉ៅ អីចិុងទៅ ។

ប៊ូលី៖ ចុះនៅក្បែរៗរហ្នឹងអត់មានការិយាល័យធ្វើការរបស់ខ្មែរក្រហមអីទេហ្ន៎?

យី ៖ អត់មានទេ! នោះផ្ទះនោះជាពាណិជ្ជកម្មរបស់គេ ។

ប៊ូលី៖ បាទ!

យី ៖ យកត្រីរុំនៅក្បាល ។

ប៊ូលី៖ យកត្រីរុំក្បាលតែម្ដងណា៎!

យី ៖ ហ្នឹងហើយ! ចេញមកគ្មានអ្នកណាចាប់អារម្មណ៍ទេណា យកមកទុកនៅឯលិចខ្លះទៅ យកទុកនៅនេះខ្លះទៅឲ្យម៉ា ។ ហើយខ្ញុំនៅធ្វើការទេ ហើយប៉ានៅកាន់ម៉ាស៊ីននៅឯស្រែ ត្រពាំងអូសឯណោះ ។

ប៊ូលី៖ ខ្ញុំអត់ដែលដឹងឈ្មោះយាយពេញ តើយាយឈ្មោះអី?

យី ៖ ខ្ញុំឈ្មោះយី ។

ប៊ូលី៖ ឈ្មោះពេញណាយាយ? ទាំងត្រកូលទាំងអី?

យី ៖ ឃៀម យី ។

ប៊ូលី៖ ឃៀម យី! ត្រកូលឃៀម?

យី ៖ ចា៎! ឪពុកខ្ញុំឈ្មោះឃៀម ។

ប៊ូលី៖ ឪពុកយាយឈ្មោះអី?

យី ៖ ឪពុកខ្ញុំឈ្មោះឃៀម ។

ប៊ូលី៖ ត្រកូលអីដែរ?

យី ៖ ត្រកូលអ៊ឹម ។

ប៉ូលី៖ អ៊ឹម យៀម? ម្ដាយយាយឈ្មោះអី?

យី ៖ ម្ដាយខ្ញុំឈ្មោះយាយអៀង ។

ប៉ូលី៖ អីអៀងដែរទៅ?

យី ៖ ឡូ!

ប៉ូលី៖ ឡូ អៀង! អត់ដែលបានដឹងថាឈ្មោះយាយត្រកូលអីត្រកូលអីទេ ។ ហើយយាយ កើតឆ្នាំប៉ុន្មាន?

យី ៖ មិនដឹងជាឆ្នាំប៉ុន្មានទេណាចៅ ។ ឆ្នាំរកា ៧៨ ។

ប៉ូលី៖ ៧៨ អត់អីទេ យើងដកទៅដឹងថាឆ្នាំប៉ុន្មានហើយ ។ ៧៨អាចថា ១៩៣៣អីហ្នឹងណាយាយ ប្រហែល ជាខ្ទង់ហឹងហើយមើលទៅ ។

យី ៖ អត់ដឹង ។

ប៉ូលី៖ ចុះតា? ឈ្មោះតាពេញឈ្មោះអី? ម៉ុត វីនចុឹងមែន?

យី ៖ ម៉ុត វីន ។

ប៉ូលី៖ យាយនឹងតាកូនទាំងអស់ប៉ុន្មាននាក់?

យី ៖ កូនច្រើនណាស់ យាយកូន ១០នាក់ណា ។

ប៉ូលី៖ យាយកូន១០នាក់?

យី ៖ ១០នាក់ អាពតយកទៅពីរ ។

ប៉ូលី៖ យាយរៀបរាប់តិច អ្នកណាខ្លះ ទី១?

យី ៖ ម៉ុត វេត ។

ប៉ូលី៖ ម៉ុត វេត! ត្រកូលម៉ុតចុឹង?

យី ៖ ចា៎! រួចហើយគន្ធរ ។

ប៉ូលី៖ ម៉ុត គន្ធរ?

យី ៖ ចា៎! ប្រុស រួចហើយបានម៉េង ហ៊ីរ ។

ប៉ូលី៖ ម៉ុត ម៉េងហ៊ីរ?

យី ៖ ចា៎! ម៉េង ហ៊ីររួចបានខាក់ ។

ប៉ូលី៖ ម៉ុត ខាក់?

យី ៖ ចា៎! ខាក់ហើយបានថាច ។

ប៉ូលី៖ ម៉ុច ថាច?

យី ៖ ចា៎! រួចហើយ ម៉ន់ ។

**បូលីៈ** ម៉ុត ម៉ង់?

**យី ៖** ចា៎! រួចទៅ សុខ ។

**បូលីៈ** ម៉ុត សុខ?

**យី ៖** ចា៎! ចោលស្រីៗអស់ប៉ុន្មានហើយ ។

**បូលីៈ** ហ្នឹងចាំរាប់តាមក្រោយ ។ ឥឡូវនៅសល់បីទៀត ។

**យី ៖** សុខទៅ បានម៉េងហ៊ុន ។

**បូលីៈ** ម៉ុត ម៉េងហ៊ុន?

**យី ៖** ចា៎! រួចទៅបាននាង ។

**បូលីៈ** ម៉ុត នាង?

**យី ៖** ចា៎! រួចទៅបានម៉ុត ដុបហ្នឹងហើយ ។

**បូលីៈ** ម៉ុត ដុបហ្នឹងចុងក្រោយគេ?

**យី ៖** ចា៎!

**បូលីៈ** ក្នុងចំណោម ១០ហ្នឹងខ្មែរក្រហមយកទៅអស់ប៉ុន្មាន?

**យី ៖** ២ ។

**បូលីៈ** អ្នកណាគេ?

**យី ៖** វេត ហើយនឹងគន្ធរបងៗគេ ។

**បូលីៈ** បងទាំងពីរហ្នឹង?

**យី ៖** ចា៎!

**បូលីៈ** ស្រី ឬក៏ប្រុស?

**យី ៖** ស្រីមួយប្រុសមួយៗកូនឆ្ងាស់ ។

**បូលីៈ** យាយស្រី៥ ប្រុស៥ចុឹង?

**យី ៖** ប្រុស៦ ស្រី៤ ។

**បូលីៈ** ចុឹងស្រី៤?

**យី ៖** ចា៎! ចញ្ចឹមកូនអត់ងាប់ហ្នឹង ។ហើយពីដើមយើងមានដឹងអីគេដូចឥឡូវណា៎ ។ សេរីតាម ចិត្តពីដើមណា ម្នាក់ៗមានកូនច្រើនសឹងអីហ្នឹង ។ ហើយចិញ្ចឹមកូនមានបេះងាប់ មានអី ណា ។

**បូលីៈ** ចិញ្ចឹមរស់ទាំងអស់ហ្ន៎?

**យី ៖** រស់ទាំងអស់ ។

**បូលីៈ** ស្លាប់តែខ្មែរក្រហមយកទៅទេហ្ន៎?

**យី** ៖ ចា៎!

**ប៊ូលី**៖ បើកុំយកទៅប្រហែលជារស់ទាំងអស់ ។

**យី** ៖ ចា៎! វេតប្ដីវាធ្វើពេទ្យ ហើយគេរើសំណាក់ពេទ្យ ជំនាន់ហ្នឹងគេអត់ឲ្យមានពេទ្យមានគ្រូ អី ។

**ប៊ូលី**៖ នៅសម័យខ្មែរក្រហមយាយនៅផ្ទះយាយនៅហ្នឹង?

**យី** ៖ ចា៎!

**ប៊ូលី**៖ នេះជាផ្ទះរបស់យាយផ្ទាល់?

**យី** ៖ ចា៎!

**ប៊ូលី**៖ ផ្ទះរាល់ថ្ងៃហ្នឹងហ្ន៎?

**យី** ៖ ចា៎!

**ប៊ូលី**៖ ផ្ទះហ្នឹងសង់ឆ្នាំប៉ុន្មានយាយ?

**យី** ៖ ៦០ ។

**ប៊ូលី**៖ ៦០?

**យី** ៖ ចា៎!

**ប៊ូលី**៖ ប៉ុន្មានខ្នង?

**យី** ៖ ២ខ្នង ។

**ប៊ូលី**៖ ២ខ្នងហ្ន៎?

**យី** ៖ ចា៎! ៣ទាំងផ្ទះបាយ ។

**ប៊ូលី**៖ បាទ! ហើយឆ្នាំ៦០ ពេលដែលខ្មែរក្រហមចូលមកហ្នឹងកូនចៅនៅជុំគ្នា?

**យី** ៖ ជុំគ្នា ។

**ប៊ូលី**៖ ទាំង១០ ហ្នឹងហ្ន៎?

**យី** ៖ ចា៎

**ប៊ូលី**៖ ហើយ១០ នាក់នៅផ្ទះតែពីរខ្នងនៅគ្រាន់ដែរហ្ន៎?

**យី** ៖ គ្រាន់ ។

**ប៊ូលី**៖ ការនៅពេលហ្នឹង?

**យី** ៖ ការបានពីរហើយ ។

**ប៊ូលី**៖ ហើយការរួចហើយនៅតែនៅជុំគ្នាទៀត?

**យី** ៖ ទេ គេទៅតាមប្ដីគេពេទ្យ ។ តាមពេទ្យ តាមប្រពន្ធគេអស់ទៅ ។

**ប៊ូលី**៖ ហើយខ្មែរក្រហមអត់ចាត់តាំងកូនយាយទៅនៅតាមកងចល័តអីទេហ្ន៎?

**យី ៖** ចាប់ទាំងអស់ ។

**ប៊ូលី៖** ចឹងទៅនៅបែកគ្នា ឬជុំគ្នា?

**យី ៖** បែកគ្នា ។ ជុំគ្នាអ្នកដែលរត់ទៅទេបានជុំគ្នាកូនមកតាមម៉ែអស់ហ្នឹងណា ។

**ប៊ូលី៖** ចុំងនៅក្នុងសម័យខ្មែរក្រហមបែកគ្នា?

**យី ៖** បែកគ្នា បែកទៅតាមកងចល័ត ។

**ប៊ូលី៖** បាទ!

**យី ៖** កូនស្រីខ្ញុំទៅជញ្ជូនគ្រាប់នៅដល់ស្រែស្បូវហ្ន៎ ។

**ប៊ូលី៖** បានឆ្ងាយផង ។

**យី ៖** ម៉េងហ៊ីនទៅជញ្ជូនគ្រាប់ឲ្យគេ នៅសល់តែកូនតូចៗទេដែលអត់ទៅណា ។ នៅតែត្រឹម ថាចចុះមកទេដែលនៅជាមួយ ។

**ប៊ូលី៖** នៅជាមួយយាយហ្ន៎?

**យី ៖** ចា៎!

**ប៊ូលី៖** ចុំងប៉ុន្មាននាក់ដែលនៅក្នុងបន្ទុកលោកយាយនៅក្នុងសម័យខ្មែរក្រហម?

**យី ៖** នៅមិនទាន់រៀបការហ្ន៎?

**ប៊ូលី៖** ដែលនៅក្នុងបន្ទុករបស់លោកយាយណា៎ ដែលលោកយាយចិញ្ចឹមនៅឡើយ?

**យី ៖** មានថាច ម៉ន់ សុខ នាង ម៉េងហ៊ីន ដុប នៅ៦ ។

**ប៊ូលី៖** នៅ៦?

**យី ៖** ចា៎!

**ប៊ូលី៖** នៅក្នុងបន្ទុករបស់យាយ?

**យី ៖** ចា៎! នៅក្នុងបន្ទុក ។

**ប៊ូលី៖** ចុំង៦ នាក់ហ្នឹងនៅជាមួយយាយហើយនឹងម៉ា?

**យី ៖** ចា៎!

**ប៊ូលី៖** ចុំង៩ នាក់ទាំងអស់?

**យី ៖** ចា៎!

**ប៊ូលី៖** ទាំងអស់គាទៀតហ្ន៎?

**យី ៖** ចា៎!

**ប៊ូលី៖** ប៉ុន្តែនៅផ្ទះនៅមានតែម៉ា ហើយនឹងយាយតាទេ?

**យី ៖** ចា៎!

បូលី: ចុីងក្មេងៗ គេឲ្យទៅតាមកងចល័តអស់ហើយ?

យី : ចា៎! ទៅតាមចល័ត ទៅតាមកងកុមារ ។

បូលី: ប៉ុន្មានថ្ងៃគេឲ្យមកលេងផ្ទះម្តង?

យី : វាអាចមកបានក៏មកៗ ហើយទៅវិញភ្លាមទៅ?

បូលី: រាល់ថ្ងៃ រឺក៏ចន្លោះថ្ងៃ?

យី : ចន្លោះថ្ងៃ ។

បូលី: ចុីងចន្លោះៗទេហ្ន៎?

យី : ចា៎!

បូលី: ពេលហ្នឹងគេឲ្យយាយធ្វើអីកាលហ្នឹង?

យី : កំលាំងទីមួយទៀតណា៎ ច្រូតស្រូវ ស្ទូង រួចហើយរួចផុតពីច្រូតទៅគេឲ្យដាំបាយ ។

បូលី: ដាំបាយ?

យី : ចា៎! ដាំបាយ ហើយហ្នឹងដាំបបរ ។ សំណាងតាល្អណាស់ គេចាត់ឲ្យនៅរោងបាយ ។

បូលី: តាណា?

យី : តាវីនណា៎ ។

បូលី: តាវីន?

យី : ចា៎! ចាត់ឲ្យនៅរោងបាយ គាត់ប្រកែក គាត់មិនព្រមទេធ្វើបានប៉ុន្មានថ្ងៃ សុំគេទៅ កាន់ខាងម៉ាស៊ីន ហ្នឹង ។ ឈប់បានប៉ុន្មានថ្ងៃគេឲ្យក្រុមបាយហ្នឹងឲ្យវៃវ៉ែក្ត ឲ្យចាប់ផ្តែអស់ រលីង ។

បូលី: ម៉េចអុីចឹង?

យី : អត់ឲ្យមានផ្តែ មិនដឹងជាយ៉ាងម៉េច ។ សំណាងគាត់បើមិនចឹងទេប្រហែលជាធ្វើតាម បញ្ញាគេហើយ ណា ។

បូលី: មានន័យថាគាត់ទៅវ៉ៃផ្តែដែរហ្ន៎?

យី : ចា៎! ហើយឈ្លបចេះតែសួរខ្ញុំថា គេចាត់តាំងឲ្យគាត់ចេញពីរោងបាយ ឬមួយក៏គាត់ ចង់ចេញពីរោង បាយ ។ ខ្ញុំថាគាត់សុំទៅខ្លួនគាត់ទេ ។

បូលី: ខ្ញុំចង់សំណេះសំណាលនិយាយលេងជាមួយយាយឲ្យបានច្រើនតិចទៀត ពីរឿងខ្មែរ ក្រហម ពីព្រោះ មិនដែលនិយាយគ្នាលេង ។

យី : ចា៎!

បូលី: ហើយកាត់ទៅកាន់ខាងម៉ាស៊ីនហ្នឹង? ម៉ាស៊ីនហ្នឹងធ្វើអីយាយ?

យី : ម៉ាស៊ីនបូមទឹកដាក់ស្រូវ ។

ប៉ូលីៈ ម៉ាស៊ីនបូមទឹកដាក់ស្រូវ?

យី ៈ ចាំ!

ប៉ូលីៈ ដល់ពេលយប់គាត់ឡើងមកសំរាកផ្ទះវិញមក?

យី ៈ ចាំ!

ប៉ូលីៈ ចុំងគេឲ្យនៅជុំគ្នាដែរ?

យី ៈ ចាំ!ជុំ ៗ

ប៉ូលីៈ គេមានឲ្យកម្មសិទ្ធឯកជនខ្លះអត់ដូចជាចាន ឆ្នាំងអី?

យី ៈ គេយកដាក់រោងបាយគេអស់ ៗ

ប៉ូលីៈ ចុះយើងបានអី?

យី ៈ យើងយកទុកដែរ ទុកមួយចំនួនហ្នឹងណាំ ៗ លាក់លួងទុកខ្លះទៅ ៗ

ប៉ូលីៈ បាទ! ចុំងយើងលាក់ទុកគ្រាន់ធ្វើម្ហូបហូបទៅណាំ?

យី ៈ ចាំ! គ្មានភ្លើង គ្មានផ្សែងទេ ៗ ប៉ុន្តែអាចដាំទឹកអីដឹកបានទៅ ៗ

ប៉ូលីៈ បាទ!

យី ៈ ខ្ញុំអាណិតម៉ាខ្លាចចិត្ត ៗ

ប៉ូលីៈ យ៉ាងម៉េចដែរយាយ?

យី ៈ ផ្ទះនៅជិតនេះ គេមានបងប្អូនគេធ្វើយោធា គេយកអង្ករយកអីមកដាំបាយ ៗ ដាំបាយទៅ យាយហ្នឹងគាត់ហៅ ម៉ែអាវេត! មកនេះ ខ្ញុំថាចាំ ៗ ហើយខ្ញុំក៏មកៗ ហើយគាត់ក៏ដួសបាយមួយចានគោមឲ្យខ្ញុំ ឲ្យខ្ញុំយកទៅជូនម៉ា ៗ ពេលទៅដល់ខ្ញុំហៅ ម៉ាៗ គាត់នៅឯគ្រែរបស់គាត់កំពុងសំរាន្ត ខ្ញុំធ្វើតែចុំងគាត់ដឹងខ្លួនភ្ញាក់ ហើយគាត់ក៏សួរខ្ញុំថា តើខ្ញុំបានបាយមកពីណា? គាត់ឃើញចុំងគាត់អរណាស់ពីព្រោះគាត់ហូបបបរយូរហើយ ៗ ហើយខ្ញុំក៏ប្រាប់គាត់ថា យាយឯងហូបទៅគេឲ្យ ៗ ហើយគាត់ពិសារជាមួយចៅដុប រួចចៅក៏សួរថាអីហ្នឹងផ្អែមម្ល៉េះ? ចុំងហើយបានអាណិតម៉ា ៗ

ប៉ូលីៈ បាទ! អាណិតគាត់ព្រោះគាត់អត់ដែលបានស្គាល់រសជាតិបាយ?

យី ៈ ចាំ! ហើយខ្លាចណាស់រឿងដែលគេតាមដានហ្នឹងណា ធ្វើអីឲ្យគាត់ពិសារហ្នឹង ៗ គេឲ្យខ្ញុំនៅរោងបាយដែរ ប៉ុនអង្ករអី បើយកយើងអាចលួចបាន ប៉ុន្តែខ្លាចតែគេដឹង ៗ

ប៉ូលីៈ បើគេដឹងគេយកទៅវៃចោលហ្នំយាយ?

យី ៈ ចាំ! ខ្លាចចុំងហ្នឹងណាបានចេះតែស៊ីទៅ

ប៉ូលីៈ បាទ!

យី ៈ ជួនសំរាំងយកទឹកចេញ នៅសល់កាកៗទុកឲ្យគាត់ហូបទៅ ៗ

បូលី៖ យាយនៅពេលបាយហ្នឹង យាយធ្វើអីខ្លះ?

យី ៖ ធ្វើបាយឲ្យពួកកុមារ ពួកមូលដ្ឋានដែលគេចុះទៅធ្វើការហ្នុំ ។

បូលី៖ ពួកទៅធ្វើការតាមស្រែ តាមអីហ្នឹងហ្នុំ?

យី ៖ ចាំ! មួយក្រុមផ្ទះបាយមួយ មួយក្រុមផ្ទះបាយមួយចឹងទៅណាំ ។

បូលី៖ កាលហ្នឹងគេបង្កើតជាសហករណ៍អីអត់យាយ?

យី ៖ សហករណ៍ហាំ?

បូលី៖ បាទ!

យី ៖ ខ្ញុំចាមច្រើន ធ្វើបាយគ្នា គ្នាថាអត់ត្រូវសាច់ជ្រូកហើយណាំ សុំអំបិលក៏មិនបានដែរ ឲ្យគ្នាស៊ីសាច់ជ្រូក ស៊ីហើយខ្ទប់មាត់រត់ ។ ហើយសុំអំបិលខ្ញុំ ខ្ញុំក៏អត់ហ៊ានឲ្យដែរខ្លាច គេដឹងគេយកខ្ញុំទៅកសាងខ្លាចគេយកឯងទៅវ៉ៃចោលទៀត ។

បូលី៖ កាលហ្នឹងយាយអាចរៀបរាប់បានអត់ ថាគេធ្វើបាបជនជាតិចាមយ៉ាងម៉េចខ្លះទៅ កាលហ្នឹង?

យី ៖ យាយអត់ដឹងដែរ ។

បូលី៖ យាយថាគេដូរផ្ទះនៅម៉េចកាលហ្នឹង?

យី ៖ ដូរពីខ្មែរមកចាម ពីចាមទៅនៅខ្មែរ ។ ជួនកាលទៅនៅជាមួយគ្នាចាមទៅនៅជាមួយខ្មែរ ផ្ទះគេធំណាំ ។

បូលី៖ យាយដឹងថាមូលហេតុអ្វីឲ្យនៅប្តូរគ្នាចឹងអត់?

យី ៖ មិនដឹងទេចៅ ។

បូលី៖ ហើយអ្នកណាជាអ្នកបញ្ជាឲ្យប្តូរចឹង?

យី ៖ គណៈគេហ្នឹង ។

បូលី៖ គណៈត្រឹមណាំទៅ?

យី ៖ គណៈមកពីពាម គណៈធំៗគេណាំ ។

បូលី៖ ហើយពេលហ្នឹងចាមហើយនឹងខ្មែរហូបរួមគ្នា?

យី ៖ ចាំ! ហូបជុំគ្នា ។

បូលី៖ ហើយហូបសាច់ជ្រូកអីយ៉ាងម៉េចទៅ?

យី ៖ ខ្លះទ្រាំមិនបានក៏ស៊ីទៅ ខ្លះទ្រាំងបានក៏ហូបសាបចឹងទៅណា ។ បើដាក់ទៅក្លួតអស់រលីង គ្មានអីក្នុងពោះរួចធ្វើការ ។ ជួនណាវាមានអំបិលវាតិចយកពីផ្ទះមក ហើយរោយៗ ក្នុងបបរតិចទៅ ។

បូលី៖ មានដែលឃើញគេយកចាមអីទៅវ៉ៃចោលអត់?

យី ៖ អត់ដែលឃើញទេ ។ គ្រាន់តែលឺ ។

បូលី៖ លឺសូរថាយ៉ាងម៉េចដែរយាយ?

យី ៈ លឺថាគេវៃទំលាក់ទឹក ។

ចូលី៖ គេមិនមែនយកទៅកប់ទេចុឹង?

យី ៈ អត់ទេ ។

ចូលី៖ ទន្លេយើងខាងក្រោយនេះហ្ន៎?

យី ៈ ទន្លេមេគង្គ យើងអត់ហ៊ានសួរ ហ៊ានដឹងអីទេ មានតែលួយស្តាប់គ្នាតិចៗ នៅកន្លែងធ្វើ ការ ។

ចូលី៖ ដែលឃើញគេធ្វើទណ្ឌកម្មអីទេយាយ?

យី ៈ ខ្ញុំអត់ដែលឃើញទេ ។

ចូលី៖ ទៅតែរោងបាយ ហើយស្ទូវស្រូវ?

យី ៈ ចា៎!

ចូលី៖ ចុះម្ហូបកាលសម័យហ្នឹងគេធ្វើអីខ្លះ?

យី ៈ ម្ហូបគេឲ្យផ្អក ឲ្យត្រីអីធ្វើចុឹងដែរ ។ គេមានពាណិជ្ជកម្មគេខាងធ្វើផ្អក ធ្វើប្រហុកអីចឹងដែរ ។ រួចហើយ គេយកមកចែកតាមរោងបាយទៅ ។ ខ្ញុំទូលពាងនែពៅ ធ្ងន់នោះធ្ងន់ ។

ចូលី៖ យកមកធ្វើអីពាងហ្នឹង?

យី ៈ យកមកចែកគ្នាស៊ីហ្នឹង ។ ដាក់នែពៅក្នុងហ្នឹង ។

ចូលី៖ បានមកនែពៅហ្នឹងពីណាមក?

យី ៈ បានពីឃ្លាំងគេ ។

ចូលី៖ ឃ្លាំងហ្នឹងនៅឯណា?

យី ៈ ឃ្លាំងគេនៅខាងកើត កណ្តាលឃុំ ។

ចូលី៖ ឃុំអីគេ?

យី ៈ ឃុំដងក្តោងហ្នឹងណា៎ ។

ចូលី៖ មានឃ្លាំងមួយ?

យី ៈ មានឃ្លាំង ។

ចូលី៖ អ្នកណាជាអ្នកគ្រប់គ្រងឃ្លាំងហ្នឹង?

យី ៈ មានមកពីនាយខ្លះ នៅហ្នឹងខ្លះ ។

ចូលី៖ បាទ! ដងក្តោងហ្នឹងមានអ្នកជម្លាសថ្មីចំណូលមកអត់?

យី ៈ មានតើ ។

ចូលី៖ មកពីខាងណាវិញ?

យី ៈ មកពីភ្នំពេញ ៧៥ ។

ប៊ូលី៖ មកពីភ្នំពេញ៧៥ហ្ន៎?

យី ៖ ចា៎!

ប៊ូលី៖ ហើយមកនៅឯណាទៅ?

យី ៖ មកនៅជាមួយយើង?

ប៊ូលី៖ ផ្ទះជាមួយយើងម្ដងហ្ន៎?

យី ៖ ចា៎! តាបានដឹកពួលជម្មៀសហ្នឹងខ្លះដែរ គេចាត់តាំងឲ្យដឹក ដឹកទៅដីរីផុង ។

ប៊ូលី៖ ទៅធ្វើអី?

យី ៖ គេដឹកឲ្យគ្នាទៅនៅឯហ្នឹងណា ទៅកន្លែងចាញ់ផាប់អស់រលីងហ្នឹង ។ ធ្វើរោងធ្វើអីឲ្យនៅ ហើយតាមិនដឹងជាវាថៃបារអី ដូចបារប្រាក់ប្រកបារ នៅតែក្បែរបារហ្នឹង ចិនអត់ហ៊ានទៅណាទេ ។ យើងមានគោរទេះ ចឹងហើយបានគេចាត់តាំងតាឲ្យដឹក ។

ប៊ូលី៖ ហើយយកទៅទម្លាក់ចោលហ្នឹងទៅ?

យី ៖ គេធ្វើតូបៗ រោងតូចៗឲ្យនៅ ។

ប៊ូលី៖ ចុះមានអ្នកភ្នំពេញមកនៅភូមិយើងអត់?

យី ៖ មាន!

ប៊ូលី៖ មាននៅផ្ទះយើងអត់?

យី ៖ អត់មានផង ខ្ញុំអត់មាននៅផង ។

ប៊ូលី៖ ចឹងអត់មាននៅជាមួយយើងទេហ្ន៎?

យី ៖ ចា៎!

ប៊ូលី៖ ការរស់នៅយាយមានជួបនិយាយជាមួយអ្នកភ្នំពេញអត់?

យី ៖ គេអត់ឲ្យនិយាយ ។ គេអត់ឲ្យយើងទៅទំនាក់ទំនងអីទេ ។

ប៊ូលី៖ គេហាមថាម៉េចខ្លះ?

យី ៖ គេថាកុំឲ្យទៅទំនាក់ទំនងអីជាមួយគេណា បើទៅជួបគ្នាទៅជួបឯវាលធ្វើការ ធ្វើការជាមួយគ្នា ។ គ្រាន់តែខ្ញុំហើយហ្នឹងបងប្អូនខ្ញុំចំបក់ហ្នឹង ក៏គេមិនចង់ឲ្យទំនាក់ទំនងដែរ ប៉ុន្តែខ្ញុំជិនះទេ មកយករទេះទៅមកយកម៉ា ។

ប៊ូលី៖ បងប្អូនយាយប៉ុន្មាននាក់ទាំងអស់?

យី ៖ ៧នាក់ ។

ប៊ូលី៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

យី ៖ ប្រុស២ ស្រី៥ ។ ឪពុកខ្ញុំខូចតាំងពីខ្ញុំចេះដើរ ។

បូលី៖ យាយកូនទីប៉ុន្មាន?

យី ៖ ខ្ញុំកូនទី៦ ។

បូលី៖ ចុះម្ដាយយាយគាត់ខូចពីពេលណា?

យី ៖ ខូចពី៨៣ ។

បូលី៖ ចុីងម្ដាយយាយគាត់ខូចក្រោយប៉ុលពតទេចុីង?

យី ៖ ចា៎! ក្រោយ ។

បូលី៖ ហើយសម័យខ្មែរក្រហមមានបានជួបបងប្អូនឪពុកម្ដាយអត់?

យី ៖ ជួប បើទៅនៅហ្នឹងហើយ ។

បូលី៖ ចុីងយាយទៅនៅហ្នឹងហើយ?

យី ៖ ចា៎!

បូលី៖ ក្នុងសម័យខ្មែរក្រហមណាយាយ ។

យី ៖ ចា៎ ខ្ញុំទៅ ។

បូលី៖ ចុីងយាយធ្លាប់ទៅលេងដែរហ្ន៎?

យី ៖ ចា៎! ទៅម្នាក់ឯង ។ ស្បៀកខោ ទៅពាក់មួកការេ ដើរទៅ គេក៏សួរថា ម៉េចហើយគេ រោយនំបញ្ចុករួចនៅ? ខ្ញុំថារោយរួចហើយ តែមិនដឹងថារោយអីទេណា ចេះតែឆ្លើយទៅ ។ ទៅដល់ហ្នឹងបងប្អូនបន្ទោសថា ទំមកធ្វើអី គេកំពុងតែតឹងយ៉ាងនេះ ។ ពេលខ្ញុំមកវិញបានក្មួយខ្ញុំគេដឹកម៉ូតូមក ។

បូលី៖ មានម៉ូតូជិះដែរហ្ន៎យាយ? សម័យខ្មែរក្រហមហ្នឹងយាយ?

យី ៖ ចា៎! គេធ្វើការ ។ គេឌុបខ្ញុំមកដាក់នៅកន្លែងទូកខ្ញុំឆ្លងមក ខ្ញុំទឹកម៉ែពេកងាប់ៗទៅ ។

បូលី៖ ខ្មែរក្រហមគេអត់ថាអីទេហ្ន៎ ពេលយើងទៅចុីង?

យី ៖ គេអត់ដឹងទេ ។

បូលី៖ គេអត់ដឹងទេ?

យី ៖ ចា៎!

បូលី៖ តែដល់ពេលយើងឆ្លងពីភូមិទៅភូមិមួយគេមានលិខិតស្នាមអីត្រឹមត្រូវមែនអត់?

យី ៖ ចា៎! តែពេលដែលយើងទៅអត់ ។

បូលី៖ ភ័យអត់ក្នុងខ្លួន!

យី ៖ ចា៎! ភ័យណា៎ ។

បូលី៖ នៅពេលទៅជួបគាត់ គាត់និយាយម៉េចដែរ?

យី ៖ គាត់អរហ្នឹងហើយ ប៉ុន្ដែគាត់អរហើយនឹងភ័យហ្នឹងស្មើរគ្នា ។

**បូលីៈ** អ្នកភ្នំពេញពេលធ្វើការតាមវាលស្រែហ្នឹង គេដាក់ការងារឲ្យធ្ងន់ជាងអ្នកមូលដ្ឋានឬក៏ ការងារប៉ុនគ្នា?

**យី :** ចា៎! ប៉ុនគ្នា ។ ដូចដកសំណាប លើកភ្លឺក៏ចុឹងដែរ ។

**បូលីៈ** ចុះការហូបចុកវិញយ៉ាងម៉េចដែរ?

**យី :** ហូបចុកដូចគ្នាដែរ ។

**បូលីៈ** ដែរលឺសូរថាអ្នកថ្មីបាត់ខ្លួនបាត់អីញឹកអត់យាយ?

**យី :** មានតើ ។ ប៉ុន្តែមិនដឹងបាត់ព្រោះតែមូលហេតុអីយើងអត់ដឹង ។

**បូលីៈ** ហើយម៉ាបូគេឲ្យធ្វើអី?

**យី :** គេរវៃអំបោះ ធ្វើក្រមា ។ ប៉ុន្តែសុំគេអត់បានទេម៉ា គេដឹងថាយើងមានហើយៗ ។

**បូលីៈ** មានហើយម៉េចយាយ?

**យី :** យើងមានរបស់ប្រើហើយ គេចែកតែអ្នកអត់មាន ។

**បូលីៈ** សុំក្រមាគេហ្ន៎?

**យី :** ចា៎! ខ្ញុំសុំឲ្យម៉ែមួយ ។

**បូលីៈ** អ្នកណាជាអ្នកគ្រប់គ្រងភូមិហ្នឹង ស្គាល់អត់យាយ?

**យី :** អត់ទេ ទៅបាត់អស់ហើយ ។

**បូលីៈ** អ្នកភូមិហ្នឹង ឬក៏អ្នកភូមិផ្សេង?

**យី :** គណៈភូមិហ្នឹងណា គេងាប់អត់ហើយណា ។

**បូលីៈ** អ្នកស្រុកហ្នឹងដែរ?

**យី :** អត់ទេអ្នកផ្សេង ។ ហើយគណៈៗគេមកពីស្រែពីអីទេ អ្នកស្រុកអត់មានធ្វើទេ ។

**បូលីៈ** ហើយតាក្រៅពីបូមទឹកដាក់ស្រែ គាត់មានធ្វើអីទៀតអត់?

**យី :** គាត់កាន់ខាងម៉ាស៊ីន ។ កាលពេលរត់ហ្នឹង ម៉ាស៊ីន ភួយ មុង អីនៅហ្នឹងស្រែទាំងអស់

**បូលីៈ** ពី៧៩ហ្នឹងហ្ន៎?

**យី :** ចា៎!

**បូលីៈ** ម៉េចបានរត់កាលហ្នឹង?

**យី :** គេឲ្យចុះគាណូត៧៩ហ្នឹងហើយ ។

**បូលីៈ** យាយរៀបរាប់សកម្មភាពនៅពេលដែលរត់ហ្នឹងបានអត់?

**យី :** គេប្រាប់ថាម៉ោងប៉ុនេះៗទៅជុំគ្នានៅវត្តព្រែកសំរោង ។ វត្តទៅពីភូមិចាមហ្នឹងទៅ រួចហើយពេលទៅដល់ហ្នឹងជួបជុំគ្នាមែន អស់រលីងពីភូមិអស់ហើយ ។ ដល់ពេលត្រលប់មកអស់រលីងរទេះគោក្របី ។

**បូលីៈ** ពេលមកដល់ភូមិវិញ?

យី ៖ ចាំ!

ប៊ូលី៖ ទៅប៉ុន្មានថ្ងៃបានត្រលប់មកវិញ?

យី ៖ ៥ ទៅ៦ថ្ងៃហ្នឹងណា ប៉ុន្តែយើងនៅយូរ នៅពេលហ្នឹងម៉ែគាត់ខូច ។

ប៊ូលី៖ ពេលហ្នឹងម៉ាចាប់ផ្ដើមឈឺ?

យី ៖ ចាំ! ចាប់ឈឺពីវត្តព្រែកសំរោង ហើយចុះកាណូតហ្នឹងតែម្ដង ។

ប៊ូលី៖ ចុះពីហ្នឹងទៅវត្តព្រែកសំរោងជិះរទេះ?

យី ៖ ចាំ!

ប៊ូលី៖ ពីព្រែកសំរោងទៅចំបក់ជិះកាណូត?

យី ៖ ចាំ! ហើយយកទៅដាក់នៅឯវត្តអន្លង់សំឡី ។

ប៊ូលី៖ មនុស្សច្រើនទេយាយ?

យី ៖ ច្រើន ខ្លះអង្គុយក្នុងល្អីរែក រែកមួយម្នាង ដូចជាជីតាចាស់ ជីដូនចាស់ ខ្លះពរ ។

ប៊ូលី៖ ចាស់ៗហ្នឹងហ្ន៎?

យី ៖ ចាំ!

ប៊ូលី៖ ហើយចុះម៉ា?

យី ៖ ម៉ាដាក់រទេះ យើងចេះតែអូសទៅ ហើយឥវ៉ាន់យើងទូលទៅ ។

ប៊ូលី៖ ហើយយើងអូសរទេះគាត់ទៅ?

យី ៖ ចាំ! ហើយរទេះហ្នឹងអត់មានកង់ទេណា៎ មានតែខ្នងទទេ ។

ប៊ូលី៖ ម៉ាឈឺប៉ុន្មានថ្ងៃបានគាត់ខូច?

យី ៖ អត់ដល់៥ថ្ងៃ ។

ប៊ូលី៖ ហើយយើងក៏ធ្វើដំណើរពីអន្លង់សំឡីទៅចំបក់ទៀតទៅ?

យី ៖ អត់ទេ មកចំបក់នៅរហូតដាច់ខ្មែរត្រឹមប៉ុណ្ណឹងតែម្ដង ។

ប៊ូលី៖ ពីអន្លង់សំឡីមកចំបក់?

យី ៖ ចាំ!

ប៊ូលី៖ ហើយពេលគាត់ខូចហ្នឹងមានធ្វើបុណ្យធ្វើទានអីអត់?

យី ៖ មាន ប៉ុន្តែធ្វើបុណ្យអត់មានលោក ។

ប៊ូលី៖ ខ្មែរក្រហមគេឲ្យធ្វើដែរហ្ន៎?

យី ៖ ពេលហ្នឹងវាសន្តិភាពហើយ ចង់ស្ងប់ហើយ ។

ប៊ូលី៖ ពេលហ្នឹងវៀតណាមចូលមកវីនៅ?

**យី ៈ** នៅទេ ។

**បូលីៈ** ហើយខ្មែរក្រហមទៅណាអស់ទៅ?

**យី ៈ** មិនដឹងជាទៅណាទេ ។

**បូលីៈ** ហើយបន្ទាប់ពីធ្វើបុណ្យឲ្យម៉ាបូហើយ យាយហើយហ្នឹងគាត់ក៏ត្រលប់មកនៅឯនេះវិញ?

**យី ៈ** ចា៎!

**បូលីៈ** ចុះកូនចៅអី ពេលរត់ទៅមានទៅជាមួយគ្នារឺក៏អត់?

**យី ៈ** ទៅទាំងអស់គ្នា ។ ទាំង៨នាក់ហ្នឹង ។

**បូលីៈ** ហើយយាយថាអ៊ំនន អ៊ំខាល់ទៅជួបហ្នឹង?

**យី ៈ** ហ្នឹងធ្វើបុណ្យរួចហើយ ស្រួលហើយ ខាល់ចង់រៀបមកផ្ទះបានដឹកដំណឹងថាម៉ាក៏នាំគ្នាមកទៅ ។ នួនទៅខាងណាវិញទេ កាលហ្នឹងគេមានគ្នីគ្នាអីទៅជាមួយគ្នា ។

**បូលីៈ** ពេលមកដល់នេះវិញ យើងមកនៅផ្ទះយើងវិញហ្ន៎យាយ?

**យី ៈ** នៅផ្ទះយើងវិញ ។

**បូលីៈ** អត់មានគេយកផ្ទះយើងទេហ្ន៎?

**យី ៈ** អត់មានយកទេ យកតែឥវ៉ាន់ដូចជាភួង មុងអីអស់រលីង ។

**បូលីៈ** ហើយយើងបានអីហូបទៅបើអស់រលីងចឹង?

**យី ៈ** ទៅច្រូតស្រូវទឹកដោះ យកមកផ្ទាប់ហើយ បាចឲ្យស្ងួតទើបបុកវា យកមកដាំបបរ ។ ដូរប្រេងកាត យកមកអុជអីចឹងដែរទៅ ហើយក៏បានជួបជុំគ្នាវិញទៅ ។ ហើយពួកកោះត្រែងមកនិយាយថា កុមារស្លាប់ក្នុងរណ្ដៅដំឡូងហ្នឹងច្រើនណាស់ ដឹកៗវាហេវទៅស្លាប់ នៅក្នុងរណ្ដៅ ខ្លះកាន់ក្តិបននោងនៅដៃនឹងក៏ស្លាប់ដែរ ដុតស៊ីមិនទាន់ទេ ។

**បូលីៈ** សព្វថ្ងៃយាយអត់ធ្វើអីទេហ្ន៎?

**យី ៈ** ចា៎! ខ្ញុំអត់ធ្វើអីទេ កូនគេមិនឲ្យធ្វើអី ។

**សមាជិកក្រុមធ្វើវេទិកាសាធារណៈ ៈ**

ឌី ខាំបូលី

ផេង ពង្សវ៉ាស៊ី

លី សុខចំរើន

លី សុខឃាង